ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# ព្រឹត្តិបត្រប្រចាំត្រីមាស

## ត្រីមាសទី១ ឆ្នាំ២០២៤



ចេញផ្សាយតាមប្រកាសលេខ
ធ៦-០១១-១២៣ ប្រ.ក
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

លេខ ៧៨

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ឡូត៍លេខ៨៨ ផ្លូវលេខ១០២ កែងនឹងផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.gov.kh |

*********

Published by

# National Bank of Cambodia

| | | |
|---|---|---|
| Address | : | #88 Street 102 Corner Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia. |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.gov.kh |



គណៈកម្មការព្រឹត្តិបត្រ — Review Commission

| | | | |
|---|---|---|---|
| ~ ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| ~ ឯកឧត្តម ស៊ុំ សន្និសិទ្ធ | និពន្ធនាយក | H.E. Dr. Sum Sannisith | Chief Editor |

# អារម្ភកថា



**លោកជំទាវបណ្ឌិត ជា សិរី**
**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

## ប្រិយមិត្តអ្នកអានជាទីមេត្រី!

នៅត្រីមាសទី១ ឆ្នាំ២០២៤ សេដ្ឋកិច្ចពិភពលោកបន្តមានកំណើន បើទោះបីជាត្រូវប្រឈមនឹងកម្រិតអត្រាការប្រាក់ខ្ពស់ ការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការលេចឡើងនូវសង្គ្រាមនៅមជ្ឈិមបូព៌ាក៏ដោយ។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ត្រូវបានគាំទ្រជាចម្បងដោយកំណើនរឹងមាំរបស់សហរដ្ឋអាមេរិក ខណៈដែលតំបន់អឺរ៉ូមានកំណើនទាប។ ទន្ទឹមនេះ ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ក្នុងនោះក៏មានតំបន់អាស៊ាន-៥ដែរនោះ សម្រេចបានកំណើនក្នុងកម្រិតមធ្យម ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃតម្រូវការក្នុងស្រុកនិងការនាំចេញ។ ធនាគារកណ្តាលភាគច្រើនបានបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត ដោយការរក្សាអត្រាការប្រាក់គោលក្នុងកម្រិតខ្ពស់ ដើម្បីឆ្លើយតបទៅនឹងភាពមិនប្រាកដប្រជានៃអតិផរណាដែលអាចកើនឡើងសារជាថ្មី។

នៅកម្ពុជា សកម្មភាពសេដ្ឋកិច្ចបានបន្តងើបឡើង ដែលត្រូវបានគាំទ្រជាចម្បងដោយកំណើនវិស័យកម្មន្តសាលកាត់ដេរ និងទេសចរណ៍។ អតិផរណាមានកម្រិតទាបជាមធ្យមត្រឹម ០,២% ដោយសារការធ្លាក់ចុះនៃថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងកម្រិតទាបនៃអតិផរណាម្ហូបអាហារ និងអតិផរណាស្នូល។ ចំណែកឯអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាពក្នុងអត្រាជាមធ្យម ៤.០៧១ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានកើនថ្លៃ ១,២% ពីអត្រា ៤.១១៩ រៀលក្នុងមួយដុល្លារអាមេរិកកាលពីត្រីមាសមុន។ ស្ថិរភាពអត្រាប្តូរប្រាក់ត្រូវបានរួមចំណែក

ដោយការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន ដែលឆ្លើយតបទៅនឹងតម្រូវការនៃប្រាក់រៀលក្នុងសេដ្ឋកិច្ច។ ជាមួយគ្នានេះ ទុនបម្រុងអន្តរជាតិរបស់កម្ពុជាក៏ត្រូវបានគ្រប់គ្រងដោយប្រសិទ្ធភាព ហើយត្រូវបានគរពូនឱ្យមានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលបានពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន។

ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បច្ចេកវិទ្យាត្រូវបានចាត់ទុកជាប្រភពថ្មីនៃកំណើន និងមូលដ្ឋាននៃការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជាបានធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ដោយបានសម្រួលនិងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។ លើសពីនេះ វិសាលភាពនៃការតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសក្នុងតំបន់ក៏ត្រូវបានពង្រីកផងដែរ ដែលជាហេតុនាំឱ្យកម្ពុជាក្លាយជាប្រទេសឈានមុខគេមួយក្នុងការតភ្ជាប់ទ្វេភាគី ដើម្បីបានផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងក្នុងការគាំទ្រវិស័យទេសចរណ៍ និងពាណិជ្ជកម្ម។ ម៉្យាងទៀត ការតភ្ជាប់នេះជាការបង្កើនជម្រើសនៃការទូទាត់ជាអន្តរជាតិរបស់កម្ពុជា ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងទៅលើប្រព័ន្ធទូទាត់ណាមួយ។ នៅចំពោះមុខការរីកចម្រើននៃបញ្ញាសិប្បនិម្មិត (AI) ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើសក្តានុពល AI ក្នុងការពង្រឹងប្រសិទ្ធភាពប្រព័ន្ធធនាគារទាំងមូល។

## ប្រិយមិត្តអ្នកអានជាទីមេត្រី!

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ ដោយរួមបញ្ចូលនូវព័ត៌មានសំខាន់ៗ ដូចជា៖ i/-ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារ ii/-បទប្បញ្ញត្តិថ្មីៗ និង iii/-សេចក្តីប្រកាសព័ត៌មាន។ល។ ខ្ញុំសង្ឃឹមថា ព្រឹត្តបត្រដែលប្រិយមិត្តអ្នកអានទាំងអស់មាននៅក្នុងដៃនាពេលនេះនឹងរួមចំណែកបង្កើតចំណេះដឹងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាការស្វែងយល់ពីគោលនយោបាយ និងសកម្មភាពការងារថ្មីៗរបស់ធនាគារជាតិនៃកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ឱ្យរីកចម្រើនឡើងជាលំដាប់ និងបោះជំហានទៅមុខយ៉ាងស្វាហាប់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ ចីរភាព និងបរិយាបន្ន។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## សូមអរគុណ!

# មាតិកា


**អារម្ភកថា**.................................................................................................... i-ii

## ❁ ផ្នែកទី១: រូបថត និងសុន្ទរកថារបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា

១.១. សុន្ទរកថាបើក លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា................. ១

១.២. សុន្ទរកថាបិទ លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា................. ៧

១.៣. សុន្ទរកថាបើក លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងសិក្ខាសាលាស្តីពី ការអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដំណាក់កាលទី៣ ........................................................................ ១៨

១.៤. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១៣ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៤ ............................................ ២៤

១.៥. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងឱកាសខួបលើកទី៤៤ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ៖ ដំណើរឆ្ពោះទៅមុខនៃប្រាក់រៀល និងប្រព័ន្ធបាគង ...................... ២៧

## ❁ ផ្នែកទី២: សេចក្តីប្រកាសព័ត៌មាន

២.១. សេចក្តីប្រកាសព័ត៌មាន ស្តីពី ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហ-ប្រតិបត្តិការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី ........................................................................ ៣២

## ❁ ផ្នែកទី៣: សកម្មភាពថ្នាក់ដឹកនាំ

៣.១. លោកជំទាវបណ្ឌិត ជា សិរី និងឯកឧត្តម Abdul Rasheed Ghaffour ទេសាភិបាលធនាគារកណ្តាលម៉ាឡេស៊ី អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហ-ប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់..................................... ៣៤

៣.២. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី ................................................................ ៣៥

៣.៣. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលអំពីបរិយាបន្នហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០២៤ នៃវេទិកាសេដ្ឋកិច្ចពិភពលោក ........ ៣៧

៣.៤. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងកិច្ចពិភាក្សាសន្និសីទថ្នាក់ទេសាភិបាលនៃស៊ាសិន ........ ៣៨

៣.៥. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាពិភាក្សា ស្តីពី "ការបង្កើតអនាគតបច្ចេកវិទ្យាហិរញ្ញវត្ថុ៖ កិច្ចពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ញាសិប្បនិម្មិត (AI)" ........ ៣៩

៣.៦. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលនៃស៊ាសិន លើកទី៤៣ ........ ៤០

៣.៧. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ........ ៤១

៣.៨. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវបណ្ឌិត អាមីដា សាល់សៃ អាលីហ្សាបាណា ........ ៤២

៣.៩. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកស្រី Eteri Kvintradze ........ ៤៤

៣.១០. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ........ ៤៦

៣.១១. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយនាយកប្រតិបត្តិនៃអង្គការ Conservation International ........ ៤៧

៣.១២. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូជួបប្រជុំពិភាក្សាការងារ ជាមួយស្ថាប័ន NPCI International Payments Limited ........ ៤៨

៣.១៣. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយក្រុមប្រឹក្សាធុរកិច្ច អាមេរិក-អាស៊ាន ........ ៤៩

៣.១៤. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ........ ៥០

៣.១៥. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម Nkubito Manzi BAKURAMUTSA ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា ..... ៥១

៣.១៦. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ..... ៥២

៣.១៧. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំប្រតិភូធនាគារជាតិនៃកម្ពុជា គោរពព្រះវិញ្ញាណក្ខន្ធព្រះសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស..... ៥៣

៣.១៨. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូអញ្ជើញគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង អតីតសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ..... ៥៤

៣.១៩. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញពិនិត្យការប្រឡងជ្រើសរើសបុគ្គលិកចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា ក្នុងក្របខ័ណ្ឌលេខាធិការ "គ"..... ៥៥

## ❁ ផ្នែកទី៤: តារាង (ភាសាខ្មែរនិងអង់គ្លេស)

៤.១. តារាងអត្រាប្តូរប្រាក់ប្រចាំខែ..... ៥៦

៤.២. ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ ..... ៥៨

៤.៣. ឥណទានផ្តល់ដោយធនាគារទទួលប្រាក់បញ្ញើតាមប្រភេទជំនួញ និងបម្រែបម្រួលប្រចាំខែ... ៥៩

៤.៤. ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអង្គការមិនមែនរដ្ឋាភិបាល ..... ៦១

៤.៥. ការផាត់ទាត់មូលប្បទានបត្រតាមរយៈសភាផាត់ទាត់..... ៦២

៤.៦. ប្រព័ន្ធធនាគារកម្ពុជា ..... ៦៤

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣
# និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤

**សូមគោរព៖**

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**



ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា។ សន្និបាតរបស់យើងប្រព្រឹត្តិទៅ បន្ទាប់ពីប្រជាជនកម្ពុជាទូទាំងប្រទេសបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤៥ នៃទិវាជ័យជម្នះ ៧ មករា (៧ មករា ១៩៧៩ - ៧ មករា ២០២៤) និងខួបលើកទី២៥ នៃទិវានយោបាយឈ្នះ-ឈ្នះ (២៩ ធ្នូ ១៩៩៨ - ២៩ ធ្នូ ២០២៣) ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានបញ្ចប់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ និងបាននាំនូវសន្តិភាពពេញលេញជាប្រវត្តិសាស្ត្រនៅកម្ពុជា។

សន្និបាតរបស់យើងនាពេលនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងអបអរសាទរនិងផ្សព្វផ្សាយលទ្ធផលការងារ ដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងដាក់ចេញទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់សំដៅសម្រេចបានជោគជ័យថ្មីបន្ថែមទៀត សម្រាប់ប្រព័ន្ធធនាគារ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាទាំងមូល។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តម ទេសាភិបាលកិត្តិយស ដែលបានដឹកនាំអនុវត្តការកែទម្រង់ ធ្វើទំនើបកម្ម សមាហរណកម្ម និងពង្រឹងប្រព័ន្ធធនាគារកម្ពុជាឱ្យមានភាពរឹងមាំក្នុងអំឡុងពេល ២៥ឆ្នាំចុងក្រោយនេះ។ សមិទ្ធផលដ៏ថ្លៃថ្លារបស់ ឯកឧត្តម ទេសាភិបាលកិត្តិយស គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍនៃប្រព័ន្ធធនាគារកម្ពុជា។ ទន្ទឹមនេះ ខ្ញុំក៏សូមសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រី-បុគ្គលិកទាំងអស់ ដែលបានខិតខំបំពេញមុខងារ-ភារកិច្ចយ៉ាងសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដែលសម្រេចបានលទ្ធផលល្អជាបន្តបន្ទាប់។



**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នាឆ្នាំ២០២៣ កន្លងទៅនេះ សេដ្ឋកិច្ចពិភពលោកបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ដែលបានបន្ទុចបង្អាក់ដល់ការងើបឡើងសេដ្ឋកិច្ចពិភពលោក ជាពិសេស ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ ដែលរួមមាន៖ ការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែននៅអឺរ៉ុប ការផ្ទុះសង្គ្រាមរវាងអ៊ីស្រាអែលនិងក្រុមហាម៉ាសនៅមជ្ឈិមបូព៌ា និងការឡើងកម្តៅនៅតំបន់អាស៊ី។ សង្គ្រាមពិតជាបង្កនូវសោកនាដកម្មដ៏ធ្ងន់ធ្ងរដល់ប្រជាជនសង្គម និងសេដ្ឋកិច្ច មិនត្រឹមតែក្នុងរយៈពេលខ្លីប៉ុណ្ណោះទេ ថែមទាំងបន្សល់ទុកនូវផលវិបាករយៈពេលវែងផងដែរ ដូចដែលកម្ពុជាធ្លាប់ជួបប្រទះចាប់ពីឆ្នាំ១៩៧០ ដល់ចុងឆ្នាំ១៩៩៨។ សន្តិភាពបន្តរក្សាបានយ៉ាងរឹងមាំ ក្រោមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ ប្រកបដោយសេរី ត្រឹមត្រូវ តម្លាភាព និងសន្តិវិធី ដែលបានធ្វើឱ្យការផ្លាស់ប្តូរក្បាលម៉ាស៊ីនរដ្ឋសភានិងរាជរដ្ឋាភិបាល នាអាណត្តិថ្មីនេះប្រព្រឹត្តទៅដោយពិលាស។ កត្តានេះបានពង្រឹងជំនឿទុកចិត្តវិនិយោគិននិងសាធារណជនមកលើកម្ពុជា និងបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាណត្តិថ្មី ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដាក់ចេញនិងអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយពិលាស ក្នុងការបន្តដំណើរលើមាគ៌ាឈានទៅសម្រេចបានតាមគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិប្រកបដោយចីរភាព បរិយាបន្ន និងសមធម៌។

កម្ពុជាពិតជាមានសំណាង ដែលបន្តរក្សាបានសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គមយ៉ាងល្អប្រសើរ ដែលពង្រឹងបានជំនឿទុកចិត្តវិនិយោគិន ព្រមទាំងទទួលបានការគាំទ្រនិងកិច្ចសហការពីគ្រប់មជ្ឈដ្ឋាន ក្នុងការបន្តបេសកកម្មជំរុញការងើបឡើងនៃសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩។ ជាលទ្ធផលកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២៣ ត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងអត្រា ៥,៥% ដែលគាំទ្រដោយការបន្តងើបឡើងនៃវិស័យទេសចរណ៍ សន្ទុះកំណើនថ្មីនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរសម្រាប់នាំចេញ កំណើនតម្រូវការក្នុងស្រុក ជាមួយនឹងការគាំទ្រក្នុងក្របខ័ណ្ឌនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចជា កំណើនចំណាយរាជរដ្ឋាភិបាល ការអនុគ្រោះផ្នែកសារពើពន្ធ និងការគាំទ្រពីប្រព័ន្ធធនាគារ ជាដើម។ អត្រាអតិផរណាបានថយចុះមកវិញត្រឹម ២,១% ធៀបនឹងអត្រាខ្ពស់ ៥,៤% កាលពីឆ្នាំ២០២២។ ខ្ញុំក៏សូមគូសរំលេចផងដែរថា

កម្ពុជារក្សាបានតម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិកឱ្យមានស្ថិរភាពល្អប្រសើរ ដោយមានអត្រាប្រែប្រួលទាបជាង ២% ប៉ុណ្ណោះ បើធៀបនឹងការប្រែប្រួលតម្លៃរូបិយប័ណ្ណនៅប្រទេសមួយចំនួន ដូចជា ប្រាក់យ៉េនជប៉ុនធ្លាក់ថ្លៃ ៩% យ៉ន់ចិនធ្លាក់ថ្លៃ ៦,៧% និងគីបឡាវធ្លាក់ថ្លៃ ២៩,៨% ក្នុងស្ថានភាពដែលប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃក្រោមឥទ្ធិពលនៃការដំឡើង និងរក្សាអត្រាការប្រាក់គោលក្នុងកម្រិតខ្ពស់។ ស្ថិរភាពអត្រាប្តូរប្រាក់បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងជំនឿទុកចិត្តវិនិយោគិន គ្រប់គ្រងសម្ពាធអតិផរណាបានមួយផ្នែកក៏ដូចជារក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អត្រាប្តូរប្រាក់ត្រូវបានសេដ្ឋវិទូ ចាត់ទុកជាសូចនាករមួយបង្ហាញពីសុខភាពសេដ្ឋកិច្ច ដូចដែលអតីតនាយកគ្រប់គ្រងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ លោក Per Jacobson ធ្លាប់បានលើកឡើងថា "ការលើកកម្ពស់តម្លៃរូបិយវត្ថុជាតិឱ្យបានល្អ ជាការងារអាទិភាពនៃការកសាងមូលដ្ឋានអភិវឌ្ឍសេដ្ឋកិច្ចជាតិ"។

ការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ជាចម្បងអាស្រ័យដោយការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន តាមរយៈការគ្រប់គ្រងចរាចរណ៍ប្រាក់រៀលសមស្រប និងការធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារប្តូរប្រាក់តាមការចាំបាច់។ ការងារនេះអាចសម្រេចទៅបានដោយសារការរក្សាបានកម្រិតខ្ពស់គ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ ដែលបានកើនដល់ប្រមាណ ២០ ប៊ីលានដុល្លារអាមេរិក ពោលគឺបានកើនឡើង ១២,៣% ធៀបនឹងឆ្នាំ២០២២ និងស្មើនឹងជាង ៧ខែ នៃការនាំចូលទំនិញនិងសេវានាគ្រាបន្ទាប់។ នៅត្រង់ចំណុចនេះ ខ្ញុំក៏សូមគូសបញ្ជាក់ផងដែរថា ភាពមិនច្បាស់លាស់នៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងការរក្សាកម្រិតខ្ពស់នៃអត្រាការប្រាក់គោលនៅក្នុងប្រទេសអភិវឌ្ឍន៍ បានបណ្តាលឱ្យទុនបម្រុងអន្តរជាតិរបស់ធនាគារកណ្តាលមួយចំនួនថយចុះគួរឱ្យកត់សម្គាល់។



**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

យើងក៏មានមោទនភាពផងដែរ ដែលប្រព័ន្ធធនាគារកម្ពុជាបន្តមានស្ថិរភាពយ៉ាងរឹងមាំ ក្នុងស្ថានភាពដែលនៅបណ្តាប្រទេសមួយចំនួន មានការដួលរលំគ្រឹះស្ថានធនាគារ ដូចជានៅសហរដ្ឋអាមេរិកនិងស្វីស ដែលបានបង្កជាការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថិរភាពហិរញ្ញវត្ថុសកល។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទាននៅកម្ពុជា ក៏រក្សាបានស្ថិរភាពល្អ បើទោះជាបានកើនឡើងបន្តិចបន្តួចចំពោះគ្រឹះស្ថានមួយចំនួន បើធៀបនឹងការកើនឡើងនៅបណ្តាប្រទេសនានា ដោយសារការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលក្នុងប្រទេសអភិវឌ្ឍន៍ចម្បងៗ ដូចជាសហរដ្ឋអាមេរិកនិងអឺរ៉ុប។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ដែលបានរួមចំណែកក្នុងការគោរពតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា និងបន្តខិតខំរក្សាស្ថិរភាពអត្រាការប្រាក់ឥណទាន។

នៅក្នុងស្ថានភាពដែលការរៀបចំឥណទានឡើងវិញ ត្រូវបានបញ្ចប់ក្រោយវិបត្តិកូវីដ-១៩ ហើយសេដ្ឋកិច្ចជាតិ តំបន់និងពិភពលោកបានប្រឈមនឹងភាពមិនច្បាស់លាស់ខ្ពស់ ជាមួយនឹងការកើនឡើងអត្រាការប្រាក់កម្ចីក្រៅប្រទេស កំណើនឥណទានបានថយចុះមកត្រឹម ៤,៨% ដែលជាអត្រាទាបបំផុតក្នុងរយៈពេលជាង ២ទសវត្សរ៍ចុងក្រោយ។ ទោះយ៉ាងណា កំណើនឥណទាននៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកជំរុញវិស័យផលិតកម្ម ដូចជា វិស័យកម្មន្តសាល និងកសិកម្ម ដែលនៅតែមានកំណើនពីរខ្ទង់។ ទន្ទឹមនេះ ឥណទានមិនដំណើរការ ក៏បានបន្តកើនឡើងផងដែរ ដែលតម្រូវឱ្យមានការយកចិត្តដាក់ខ្ពស់លើការត្រួតពិនិត្យធនាគារ ការធ្វើ Stress Test ជាប់ជាប្រចាំ ការតាមដានវាយតម្លៃឱ្យបានស៊ីជម្រៅលើហានិភ័យប្រទាក់ក្រឡា ក៏ដូចជាទាមទារឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានការប្រុងប្រយ័ត្នខ្ពស់បន្ថែមទៀត។

ប្រឈមនឹងបញ្ហាទាំងនេះ ធនាគារជាតិនៃកម្ពុជាបានកែសម្រួលការវាយតម្លៃហានិភ័យឥណទាន ដោយបន្ទាបហានិភ័យក្នុងការផ្តល់ឥណទានទៅកាន់វិស័យអាទិភាព ដូចជា កសិកម្ម អប់រំ និងសហគ្រាសធុនតូច និងមធ្យម ជាដើម។ ទន្ទឹមនេះ បទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនត្រូវបានអនុគ្រោះ ដើម្បីផ្តល់សន្ទនីយភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកាន់តែច្រើន ក្នុងការរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច ក៏ដូចជាពង្រឹងការការពារហានិភ័យនានា ដូចជា ការបន្តអនុវត្តទ្រនាប់ដើមទុនខនស៊ើវេសិនត្រឹម ១,២៥% ការបន្ធូយអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណមក ៧% និងការអនុញ្ញាតឱ្យរៀបចំឥណទានឡើងវិញ ចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប។ ដោយឡែក ធនាគារជាតិនៃកម្ពុជា ក៏បានបន្តលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុនៅទូទាំងប្រទេស ក្នុងរូបភាពផ្សេងៗ ដូចជាការផ្សព្វផ្សាយក្នុងវេទិកានិងយុទ្ធនាការនានា ក៏ដូចជាកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធដែលរួមមាន ក្រសួងអប់រំយុវជននិងកីឡាលើការបញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅ និងកិច្ចសហការជាមួយក្រសួងកិច្ចការនារីលើការលើកកម្ពស់ហិរញ្ញប្បទានស្ត្រី និងសហគ្រិនស្ត្រី។

ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចាប់ឱកាស អភិវឌ្ឍប្រព័ន្ធទូទាត់ជាលំដាប់ ដែលបានធ្វើឱ្យការទូទាត់កាន់តែងាយស្រួល សុវត្ថិភាព និងឆាប់រហ័ស ដោយបានដោះស្រាយឧបសគ្គក្នុងការទូទាត់ឆ្លងគ្រឹះស្ថាន និងការយកថ្លៃសេវាខ្ពស់។ ប្រសិទ្ធភាពនៃប្រព័ន្ធទូទាត់បានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការដោះដូរទំនិញនិងសេវា បរិយាបន្នហិរញ្ញវត្ថុ និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដែលគាំទ្រដល់គោលដៅអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាល។ ម្យ៉ាងទៀត ការតភ្ជាប់ប្រព័ន្ធទូទាត់កម្ពុជាជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់ ក៏ត្រូវបានពង្រឹងនិងពង្រីក ដែលបានចូលរួមលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការបង្វែរប្រាក់ពីក្រៅប្រទេស។ បច្ចុប្បន្ន យើងបានតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសថៃ វៀតណាម និងឡាវ ព្រមទាំងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិមួយចំនួន ហើយក្នុងឆ្នាំនេះ យើងនឹងអាចតភ្ជាប់ជាមួយប្រទេសឥណ្ឌា និងចិន ជាមួយនឹងផែនការតភ្ជាប់ជាមួយប្រទេសផ្សេងទៀតក្នុងតំបន់។ ការតភ្ជាប់នេះនឹងបើកលទ្ធភាពឱ្យប្រជាជនកម្ពុជា អាចទូទាត់តាមប្រព័ន្ធយូអរកូតចេញពីគណនីប្រាក់រៀលរបស់ខ្លួន នៅតាមបណ្តាហាងទំនិញរាប់លានកន្លែង ហើយក៏ផ្តល់លទ្ធភាពឱ្យប្រជាជននៅក្នុងប្រទេសនិងបណ្តាញដែលកម្ពុជាបានភ្ជាប់ប្រព័ន្ធទូទាត់ជាមួយ អាចទូទាត់នៅកម្ពុជាបានដោយងាយស្រួល។

នៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិវិញ ក្រោយពីបានបំពេញតួនាទីជាប្រធានអាស៊ានសម្រាប់វិស័យធនាគារក្នុងឆ្នាំ២០២២ ដោយជោគជ័យ ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងសមាហរណកម្ម និងស្ថិរភាពហិរញ្ញវត្ថុតំបន់ ជាពិសេសនៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោក កំពុងប្រឈមនឹងការកើនឡើងហានិភ័យនៃការបែងចែកភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជាខ្ពស់។ ម៉្យាងទៀត ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងការផ្តួចផ្តើមគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា និងសហការជាមួយអង្គការនិងស្ថាប័នអន្តរជាតិដូចជា UNESCAP និង IFC ជាដើម ក្នុងការរៀបចំផែនទីមគ្គុទ្ទេសក៍ហិរញ្ញប្បទានប្រកបដោយចីរភាពកម្ពុជា សំដៅគាំទ្រសេដ្ឋកិច្ចបៃតង កិច្ចការពារបរិស្ថាន និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ទន្ទឹមនេះ ការពង្រឹងកាតព្វកិច្ចអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក៏បានរួមចំណែកមិនអាចខ្វះបានផងដែរ ក្នុងការធានានូវតម្លាភាពនិងចីរភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាជំនឿទុកចិត្តពីសាធារណជន និងវិនិយោគិនមកលើប្រព័ន្ធធនាគារកម្ពុជា។ ជាក់ស្តែង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយបានឈានទៅដល់ការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) កាលពីដើមឆ្នាំ២០២៣។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

លទ្ធផលដែលយើងសម្រេចបាននាឆ្នាំ២០២៣ ជាសមិទ្ធផលដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីសាមគ្គីភាពនិងការទទួលខុសត្រូវខ្ពស់របស់យើងទាំងអស់គ្នា។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និង

ភាគីពាក់ព័ន្ធ ដែលបានរួមចំណែកក្នុងការសម្រេចបានសមិទ្ធផលទាំងនេះ សម្រាប់ជាប្រយោជន៍ដល់ការរីកចម្រើននៃប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចជាតិទាំងមូល។

ដើម្បីជ្រាបពីសមិទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារចម្បងៗ ខ្ញុំសូមឱ្យអង្គសន្និបាតត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងរយៈពេល ២ថ្ងៃនេះ។

ខ្ញុំសូមជូនពរឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យនិងផ្លែផ្កា។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**






# សុន្ទរកថាបិទ
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣
# និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤

**សូមគោរព៖**

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**



សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា បានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព និងភាពស្និទ្ធស្នាល។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកជាសមាជិក-សមាជិកាអង្គសន្និបាតទាំងអស់ដែលបានធ្វើបទអន្តរាគមន៍ និងចូលរួមយ៉ាងយកចិត្តទុកដាក់ក្នុងសន្និបាតនារយៈពេលពីរថ្ងៃកន្លងមកនេះ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតទាំងអស់ ពិតជាបានយល់កាន់តែច្បាស់ពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការអនុវត្តនយោបាយនានា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបាននិងកំពុងកើតឡើង ព្រមទាំងក្តាប់បាននូវទិសដៅការងារចម្បងៗសម្រាប់យកទៅអនុវត្តនាពេលខាងមុខ សំដៅបន្តរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារកម្ពុជាឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត។ ខ្ញុំសូមស្នើឱ្យថ្នាក់ដឹកនាំតាមបណ្តានាយកដ្ឋាន អង្គភាពនិងសាខាធនាគារជាតិនៃកម្ពុជាទាំងអស់ ផ្សព្វផ្សាយបន្តនូវខ្លឹមសារនៃអង្គសន្និបាតរបស់យើងនាពេលនេះ ឱ្យបានទូលំទូលាយដល់មន្ត្រី-បុគ្គលិកទាំងអស់ ដើម្បីយល់ច្បាស់ពីទិសដៅរួមរបស់យើងទាំងអស់គ្នា។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកយើងទាំងអស់ ដែលបានយកចិត្តទុកដាក់បំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ និងសាមគ្គីភាព ដោយទទួលបានលទ្ធផលគួរជាទីមោទនៈក្នុងការរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ក៏ដូចជាគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច។ ការសម្រេចបានលទ្ធផលល្អទាំងនេះ មិនអាចកាត់ផ្តាច់ចេញបានពីផ្លែផ្កានៃសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ចំពោះទស្សនវិស័យឆ្នាំ២០២៤នេះ សេដ្ឋកិច្ចពិភពលោកនៅបន្តប្រឈមនឹងភាពមិនច្បាស់លាស់ជាច្រើន រួមមាន៖ i/- ភាពតានតឹងភូមិសាស្ត្រនយោបាយ (Geopolitical tension) និងហានិភ័យនៃការបែងចែកភូមិសាស្ត្រនយោបាយ (Geopolitical fragmentation) ដែលនាំទៅរកការធ្លាក់ចុះលំហូរពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ និងទេសចរណ៍ និង ii/- ភាពមិនច្បាស់លាស់លើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ដោយសារការរំពឹងទុកនៃការធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុនៅប្រទេសអភិវឌ្ឍន៍ធំៗ ក្រោយពីអត្រាអតិផរណានៅក្នុងប្រទេសទាំងនោះថយចុះដល់កម្រិតគោលដៅ។ ដូច្នេះ លំហូរមូលធនអាចនឹងមានការប្រែប្រួលទៅតាមល្បឿននៃការធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុ និងអាចនាំឱ្យមានភាពមិនច្បាស់លាស់លើលំហូរវិនិយោគ និងសម្ពាធលើអត្រាប្តូរប្រាក់។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចកម្ពុជាអាចបន្តប្រឈមនឹងហានិភ័យខាងក្រៅខ្ពស់។





ម៉្យាងទៀត ហានិភ័យខាងក្នុង ក៏អាចជាបញ្ហាប្រឈមផងដែរ រួមមាន៖ i/- ការងើបឡើងទន់ខ្សោយនៃវិស័យសំណង់ និងការថយចុះតម្រូវការក្នុងវិស័យអចលនទ្រព្យ ដែលជាចម្បងដោយសារវិបត្តិក្នុងវិស័យអចលនទ្រព្យ និងការបន្ថយល្បឿនកំណើនសេដ្ឋកិច្ចនៅប្រទេសចិន ដែលជាប្រទេសវិនិយោគដ៏ធំមួយសម្រាប់កម្ពុជា។ លំហូរទាបនៃការវិនិយោគបរទេសទៅកាន់វិស័យអចលទ្រព្យ នឹងនាំឱ្យថយចុះប្រភពចំណូលមួយគាំទ្រដល់តម្រូវការអចលទ្រព្យក្នុងស្រុកផងដែរ ii/- ពិតមែនតែចំនួនភ្ញៀវទេសចរបានកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែការចំណាយរបស់ភ្ញៀវទេសចរជាមធ្យម ត្រូវបានប៉ាន់ស្មានថាមានកម្រិតទាបជាងមុនពេលវិបត្តិកូវីដ ដោយសារតែភាគច្រើននៃភ្ញៀវទេសចរអន្តរជាតិគឺបានចូលមកកម្ពុជាតាមផ្លូវគោក ពីប្រទេសជិតខាង ដែលការស្នាក់នៅមានរយៈពេលខ្លី។ ប្រសិនបើចំនួនភ្ញៀវទេសចរចូលកម្ពុជាតាមផ្លូវអាកាសនៅបន្តកើនឡើងយឺត ដូច្នេះ នឹងអាចបន្តដាក់សម្ពាធដល់វិស័យដែលទទួលផលពីភ្ញៀវទេសចរទាំងនោះ ជាពិសេស វិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងអាជីវកម្មលក់គ្រឿងអនុស្សាវរីយ៍ ជាដើម iii/- ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ អត្រាឥណទានមិនដំណើរការបានកើនឡើង ដែលជាឥទ្ធិពលដក់សល់ពីវិបត្តិកូវីដ-១៩ និងការថយចុះកំណើនឥណទាន។ ពិតមែនតែឥណទានមិនដំណើរការ បន្តស្ថិតក្នុងកម្រិតគ្រប់គ្រងបាន ប៉ុន្តែការកើនឡើងនៃអត្រា

ឥណទានមិនដំណើរការអាចនាំទៅរកការថយចុះលទ្ធភាពស្វែងរកប្រាក់ចំណេញ ក៏ដូចជាផលវិបាកលើការបង្កើនល្បឿនកំណើនឥណទាន ដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ច iv/- វិបត្តិកូវីដ-១៩ បានរួមចំណែកបង្កើនបំណុលក្នុងវិស័យឯកជន ជាពិសេសបំណុលគ្រួសារ ប៉ុន្តែនៅស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ ត្រង់ចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ថា កន្លងមកមានអង្គការក្រៅរដ្ឋាភិបាលមួយបានលើកឡើងថា អ្នកខ្ចីប្រាក់ភាគច្រើនជាប់ជំពាក់បំណុលច្រើនលើសលប់ ហើយចំណាយប្រាក់ចំណូលរបស់ពួកគេជាង៧០% លើការបង់សងបំណុលគ្រឹះស្ថានហិរញ្ញវត្ថុ។ ជាក់ស្តែង របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលនេះ នៅមានចំណុចខ្វះខាតជាច្រើន ជាពិសេសដោយសារតែការអង្កេតនេះ ធ្វើឡើងតែនៅក្នុងខេត្តកំពង់ស្ពឺតែប៉ុណ្ណោះ ជាមួយនឹង ៧១៧គ្រួសារ ហើយកម្រងសំណួរទៀតសោតមិនបានផ្តល់ជម្រើសគ្រប់គ្រាន់ដល់អ្នកឆ្លើយទេ។ ផ្ទុយទៅវិញ ដោយយោងទៅតាមទិន្នន័យជាក់ស្តែងលើគណនីអតិថិជនជាង ៤ម៉ឺនគណនី ដែលបានដកស្រង់ចេញពីឥណទានលំនៅឋានរបស់ធនាគារពាណិជ្ជ ផ្អែកលើទិន្នន័យសន្ទស្សន៍ថ្លៃលំនៅឋានចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២២ បានបង្ហាញថា អ្នកខ្ចីប្រាក់ប្រមាណ ២៥% ប៉ុណ្ណោះ ដែលបានប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេលើសពី ៤០% ដើម្បីសងបំណុល ខណៈដែលមានអ្នកខ្ចីប្រាក់ត្រឹមតែ ៦% ដែលបានប្រើប្រាស់ប្រាក់ចំណូលលើសពី ៦០% ដើម្បីសងបំណុល និង v/- វិស័យកសិកម្មនៅតែបន្តពឹងផ្អែកខ្លាំងលើការប្រែប្រួលអាកាសធាតុ ហើយនៅឆ្នាំ២០២៤នេះ ការប៉ាន់ស្មានលើភាពគំរាមកំហែងនៃអាកាសធាតុមិនអំណោយផល ដោយសារបាតុភូតអែលនីញ៉ូត្រូវបានព្យាករថានឹងមានឥទ្ធិពលខ្លាំងជាងឆ្នាំ២០២៣ ដែលធ្វើឱ្យកម្តៅកើនឡើងខ្ពស់ជាងធម្មតារហូតដល់ ៧អង្សារ (Celsius) កម្រិតទឹកភ្លៀងទាបនិងអាចបង្កឱ្យមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរ។ ឥទ្ធិពលនេះអាចនឹងផ្តល់ផលប៉ះពាល់ដល់ទិន្នផលកសិកម្ម និងជលផល ដែលនឹងដាក់សម្ពាធលើថ្លៃម្ហូបអាហារ។

ទោះជាប្រឈមនឹងបញ្ហាទាំងនេះក៏ដោយ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករដោយសុទិដ្ឋិនិយមថានឹងកើនឡើងក្នុងរង្វង់ ៦,៤% នៅឆ្នាំ២០២៤ ដែលរួមចំណែកជាចម្បងដោយការបន្តកើនឡើងនៃវិស័យសេវាកម្ម ជាពិសេស វិស័យទេសចរណ៍ និងការងើបឡើងនៃវិស័យកម្មន្តសាល ស្របពេលដែលវិស័យកសិកម្ម សំណង់ និងអចលនទ្រព្យបន្តទទួលបានកំណើនទាប។

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងសន្ទុះកំណើននិងរក្សាស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន ពង្រឹងការអភិវឌ្ឍប្រព័ន្ធធនាគារ លើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាព និងសមាហរណកម្មនៃប្រព័ន្ធទូទាត់ ព្រមទាំងត្រៀមខ្លួនដាក់ចេញនូវនយោបាយនិងវិធានការគាំទ្រចាំបាច់នានា ប្រកបដោយភាពបុរេសកម្ម ស្របតាមស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងទិសដៅនេះ ខ្ញុំសូមលើកឡើងនូវការងារចម្បងៗមួយចំនួន ដែលធនាគារជាតិនៃកម្ពុជានឹងត្រូវអនុវត្តដូចតទៅ៖

១/- លើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់៖ ការរក្សាស្ថិរភាពតម្លៃប្រាក់រៀលនឹងបន្តជាជម្រើសនយោបាយសមស្រប ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃនិងការពារអំណាចទិញនិងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ធនាគារជាតិនៃកម្ពុជានឹងត្រូវបន្តអនុវត្តនយោបាយរូបិយវត្ថុផ្អែកលើការរក្សាអត្រាប្តូរប្រាក់ក្រោមរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប និងធ្វើអន្តរាគមន៍តាមការចាំបាច់ ផ្អែកតាមស្ថានភាពទីផ្សារ។ ក្នុងទិសដៅនេះ ខ្ញុំសូមស្នើឱ្យមានការចូលរួមកាន់តែសកម្មលើ៖

- ការបន្តអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយពីគ្រប់មជ្ឈដ្ឋាន
- ការអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុ ទីផ្សារប្តូរប្រាក់ និងទីផ្សារអន្តរធនាគារ និង
- ការអភិវឌ្ឍក្របខ័ណ្ឌនយោបាយរូបិយវត្ថុ ដោយបង្កើតឱ្យមានអត្រាការប្រាក់គោល របស់ធនាគារកណ្តាល ដើម្បីតម្រង់ទិសអត្រាការប្រាក់ជារៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ការងារទាំងនេះ អាចសម្រេចទៅបានដោយជោគជ័យ គឺអាស្រ័យលើការគាំទ្រនិងកិច្ចសហការពីភាគីពាក់ព័ន្ធទាំងអស់ ដែលទាមទារឱ្យមានការពង្រឹងការទំនាក់ទំនងជាប់ជាប្រចាំ អំពីគោលនយោបាយនិងវិធានការរបស់ធនាគារជាតិនៃកម្ពុជា។







២/- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ៖ ស្ថិតក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់សេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ការវិនិយោគទុនបម្រុងអន្តរជាតិអាចមានបញ្ហាប្រឈមច្រើន ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ និងតាមដានជាប្រចាំពីសភាពការណ៍ទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ព្រមទាំងគោរពតាមគោលការណ៍អាទិភាព គឺសុវត្ថិភាព សន្ទនីយភាព និងចំណូល។

៣/- ការពង្រឹងការត្រួតពិនិត្យប្រព័ន្ធធនាគារ៖ ប្រព័ន្ធធនាគារបានគាំទ្រយ៉ាងសកម្មដល់ការងើបឡើងនៃសេដ្ឋកិច្ច ទាំងក្នុងអំឡុងវិបត្តិកូវីដ-១៩ និងដំណាក់កាលងើបឡើងវិញពីវិបត្តិ។ ទោះយ៉ាងណា ប្រព័ន្ធធនាគារក៏បាននិងកំពុងប្រឈមនឹងការកើនឡើងឥណទានមិនដំណើរការ និងឥទ្ធិពលនៃកម្រិតអត្រាការប្រាក់ខ្ពស់នៅលើពិភពលោកផងដែរ។ ខ្ញុំសូមស្នើឱ្យបន្តពង្រឹងការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត អនុវត្តការធ្វើស្ត្រេសតេស្តជាប្រចាំលើភាពរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងដាក់ចេញវិធានការម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នដែលមានលក្ខណៈបុរេសកម្ម ដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធធនាគារ និងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុដែលនឹងគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ជាមួយគ្នានេះ យើងក៏ត្រូវតាមដាននិងវាយតម្លៃស្ថានភាព ដើម្បីបន្តដាក់ចេញយុទ្ធសាស្ត្រចាកចេញពីវិបត្តិដោយប្រុងប្រយ័ត្ន ស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤/- ការអភិវឌ្ឍប្រព័ន្ធទូទាត់៖ ប្រព័ន្ធទូទាត់សងប្រាក់កម្ពុជាបាននិងកំពុងចាប់យកកាលានុវត្តភាព និងទាញយកសក្តានុពលពីការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល ដែលបានធ្វើឱ្យការទូទាត់កាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងជំរុញសេដ្ឋកិច្ចឌីជីថល ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តជំរុញអន្តរប្រតិបត្តិការ និងការតភ្ជាប់នៃប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ប្រសិទ្ធភាពប្រព័ន្ធទូទាត់ និងសមាហរណកម្មក្នុងតំបន់និងពិភពលោក សំដៅរួមចំណែកក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការបង្វែរប្រាក់ពីក្រៅប្រទេស។ ជាមួយនឹងនវានុវត្តន៍នៃប្រព័ន្ធទូទាត់អេឡិចត្រូនិក យើងក៏ត្រូវបង្កើនការយកចិត្តទុកដាក់ពង្រឹងប្រព័ន្ធការពារសុវត្ថិភាពបច្ចេកវិទ្យា និងគ្រប់គ្រងហានិភ័យប្រតិបត្តិការឱ្យកាន់តែមានប្រសិទ្ធភាពនិងទាន់ពេលវេលា ដើម្បីធានាដំណើរការដោយពិលាសនៃសេវាហិរញ្ញវត្ថុឌីជីថល ពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ។

គួរបញ្ជាក់ថា ប្លុកឆេនគឺជាបច្ចេកវិទ្យាដ៏ទំនើបមួយដែលយើងអាចប្រើប្រាស់សម្រាប់អភិវឌ្ឍប្រព័ន្ធទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃទាប ដូចជាប្រព័ន្ធបាគង ដែលបានក្លាយជាប្រព័ន្ធទូទាត់កន្លោងសម្រាប់សម្រួលដល់ការទូទាត់អន្តរគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការទូទាត់ឆ្លងប្រទេសផងដែរ។ ដោយឡែកទ្រព្យសកម្មគ្រីបតូគឺជាទ្រព្យសកម្មឌីជីថលដែលមិនមានប្រភពច្បាស់លាស់ និងមានហានិភ័យខ្ពស់ ហើយធនាគារជាតិនៃកម្ពុជាមិនអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានប្រតិបត្តិការពាក់ព័ន្ធនឹងគ្រីបតូឡើយ ដើម្បីទប់ស្កាត់ហានិភ័យដល់សាធារណជន ដែលអាចងាយរងការឆបោក និងការខាតបង់ផ្សេងៗ។

៥/- ការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់៖ ទន្ទឹមនឹងនិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃការទូទាត់តាមប្រព័ន្ធឌីជីថល ការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ត្រូវបន្តយកចិត្តទុកដាក់អនុវត្តជាប្រចាំ ដើម្បីបំពេញតម្រូវការសាធារណជនទូទាំងប្រទេស។ កន្លងមក យើងបានអនុវត្តការងារគ្រប់គ្រងការចរាចរសាច់ប្រាក់បាន

យ៉ាងល្អប្រសើរ និងបានលើកកម្ពស់គុណភាពនិងសោភ័ណភាពក្រដាសប្រាក់រៀលជាលំដាប់ ដែលឆ្លុះបញ្ចាំងតាមរយៈការឈ្នះពានរង្វាន់អន្តរជាតិជាបន្តបន្ទាប់។ ខ្ញុំសូមស្នើឱ្យបន្តយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សេវាបង់និងបើកសាច់ប្រាក់ ការគ្រប់គ្រងនិងថែរក្សាសុវត្ថិភាពឃ្លាំងបេឡា និងការដឹកជញ្ជូនធនបត្រ ដោយឆ្លើយតបឱ្យបានទាន់ពេលវេលាដល់តម្រូវការសាច់ប្រាក់ ព្រមទាំងជួយសម្រួលដល់ការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែក នៅតាមបណ្តាសាខារាជធានី-ខេត្តឱ្យបានទូលំទូលាយ។ ជាមួយគ្នានេះ យើងត្រូវជំរុញការបញ្ចេញក្រដាសប្រាក់រៀលដែលមានតម្លៃចារឹកធំៗ ដូចជា ក្រដាសប្រាក់ ៥ម៉ឺនរៀល និង ១០ម៉ឺនរៀល ឱ្យបានកាន់តែច្រើនទៅក្នុងទីផ្សារ ដើម្បីឱ្យសាធារណជននិងអាជីវករមានទម្លាប់ក្នុងការចាយជាប្រាក់រៀលធំៗ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួលក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់ជារូបិយវត្ថុជាតិ។

៦/- ការពង្រឹងប្រសិទ្ធភាពនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលបានដើរតួនាទីយ៉ាងសំខាន់លើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយបានរៀបចំទទួលការចុះមកត្រួតពិនិត្យដល់ទីកន្លែងនៅកម្ពុជា របស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបំពេញតាមលក្ខខណ្ឌចាំបាច់នានារហូតសម្រេចបានជោគជ័យក្នុងការដកកម្ពុជាចេញពីបញ្ជីប្រផេះ របស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។ ខ្ញុំសូមស្នើឱ្យបន្តយកចិត្តទុកដាក់ពិនិត្យតាមដានការអនុវត្តច្បាប់របស់បុគ្គលរាយការណ៍ និងសហការឱ្យបានសកម្មជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងស្រុកនិងអន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឱ្យកាន់តែមានប្រសិទ្ធភាព ដែលនឹងធានាបាននូវសុចរិតភាពនៃប្រព័ន្ធធនាគាររបស់យើង។

៧/- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន៖ បរិយាបន្នហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ ស្របតាមកំណើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ភាពប្រសើរឡើងនៃអក្ខរកម្មហិរញ្ញវត្ថុ និងការពង្រីកបណ្តាញប្រតិបត្តិការនិងសេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទោះយ៉ាងណា ការទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមរម្យ ក៏ដូចជាចំណេះដឹងហិរញ្ញវត្ថុនៅតាមទីជនបទចំពោះសហគ្រាសធុនមីក្រូ តូច និងមធ្យម នៅមានកម្រិតនៅឡើយ។ ហេតុដូចនេះ ខ្ញុំសូមស្នើឱ្យបន្តលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយ និងត្រូវអនុវត្តជាប្រចាំ នៅទូទាំងប្រទេស ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ ដូចជា គ្រឹះស្ថានអប់រំ និងរោងចក្រ-សហគ្រាសជាដើម។ ជាមួយនឹងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ កិច្ចការពារអតិថិជនក៏ទាមទារនូវការយកចិត្តទុកដាក់អនុវត្តផងដែរ ដើម្បីធានាថាអតិថិជនអាចទទួលបានការការពារយ៉ាងដិតដល់លើការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ និងពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា។ ខ្ញុំសូមក្រុមការងារទទួលបន្ទុកហតឡាញ (Hotline) បន្តរួមចំណែកឆ្លើយនឹងសំណួររបស់សាធារណជន និងសម្របសម្រួលដោះស្រាយបណ្តឹង ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។



៨/- ការលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាព៖ បច្ចុប្បន្ន ពិភពលោកបាននិងកំពុងប្រឈមនឹងហានិភ័យបង្កឡើងដោយការប្រែប្រួលអាកាសធាតុ ដែលបានបង្កផលប៉ះពាល់មកលើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនានានៅលើពិភពលោកបានដាក់ចេញនូវគំនិតផ្តួចផ្តើមផ្សេងៗ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយភាពធន់ និងអាចចូលរួមក្នុងការកៀរគរហិរញ្ញប្បទាន សម្រាប់សកម្មភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ ដូចនេះ ធនាគារជាតិនៃកម្ពុជានឹងចូលរួមចំណែកបង្កើតឱ្យមានយន្តការគាំទ្រ និងប្រព័ន្ធអេកូឡូស៊ីចាំបាច់ ដើម្បីជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព និងសកម្មភាពជាសារវន្តក្នុងការការពារហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតផែនទីមគ្គុទេសក៍ ប្រព័ន្ធវគ្គីករសាស្ត្រ និងយន្តការរាយការណ៍សម្រាប់ហិរញ្ញប្បទានប្រកបដោយចីរភាព ព្រមទាំងលើកកម្ពស់ការកសាងសមត្ថភាព និងចំណេះដឹងដល់ប្រព័ន្ធធនាគារនិងភាគីពាក់ព័ន្ធ និងពង្រឹងក្របខ័ណ្ឌវាយតម្លៃនិងការពារហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

៩/- ការលើកកម្ពស់ប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជា៖ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះការពង្រឹងប្រតិបត្តិការនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក្នុងការរួមចំណែកគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ នៅក្នុងប្រព័ន្ធធនាគារឱ្យកាន់តែមានប្រសិទ្ធភាព សំដៅគាំទ្រការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់។ ខ្ញុំសូមស្នើឱ្យសាខាទាំងអស់បន្ត៖ i/-លើកកម្ពស់គុណភាពសេវាជូនមន្ទីរ-អង្គភាពរបស់រាជរដ្ឋាភិបាល និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសការទទួលនិងការបើកសាច់ប្រាក់និងការគ្រប់គ្រងគណនី និងការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក ជូនដល់សាធារណជន ii/-ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមន្ទីរ-អង្គភាព ក្នុងការអនុវត្តមុខងារ-ភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសការរួមចំណែកអនុវត្តការកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល iii/-ពង្រឹងការផ្តល់ព័ត៌មានអំពី

ការប្រើប្រាស់សេវាហិរញ្ញវត្ថុតាមប្រព័ន្ធទូរសព្ទហតឡាញ (Hotline) iv/-ចូលរួមចំណែកតាមដានស្ថានភាពសេដ្ឋកិច្ចនៅតាមរាជធានី-ខេត្តនីមួយៗ និង v/-លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។ នាថ្ងៃខាងមុខ យើងក៏មានផែនការពង្រីកបណ្ដាញសាខាធនាគារជាតិនៃកម្ពុជា នៅតាមបណ្ដាខេត្តមួយចំនួន ដូចជា ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ និងត្បូងឃ្មុំ ជាដើម ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនៅតាមបណ្ដាខេត្តទាំងនោះឱ្យបានកាន់តែប្រសើរ។

១០/- ការគ្រប់គ្រងនិងបណ្ដុះបណ្ដាលធនធានមនុស្ស៖ ការអភិវឌ្ឍធនធានមនុស្ស គឺជាការងារអាទិភាពដ៏សំខាន់ ដែលយើងត្រូវអនុវត្តជាប្រចាំ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបំពេញមុខងារ-ភារកិច្ចរបស់ធនាគារកណ្ដាល ស្របតាមការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ការកើនឡើងនៃសមាហរណកម្មទៅក្នុងតំបន់ និងនវានុវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកយើងដែលបានអភិវឌ្ឍចំណេះដឹងជាលំដាប់ ទាំងជំនាញឯកទេសនិងជំនាញផ្សេងៗទៀត ដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពការងារ ជាពិសេសក្នុងយុគសម័យឌីជីថល។ ខ្ញុំសូមស្នើឱ្យបន្តពង្រឹងយន្តការអភិវឌ្ឍចំណេះជំនាញថែមទៀត និងលើកទឹកចិត្តមន្ត្រីបុគ្គលិកខិតខំអភិវឌ្ឍសមត្ថភាព ដើម្បីសម្រួលដល់ការបំពេញការងារឱ្យបានល្អប្រសើរ។

១១/- ការលើកកម្ពស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ៖ ក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ មណ្ឌលសិក្សាបច្ចេកទេសធនាគារ បានដើរតួនាទីយ៉ាងសកម្មក្នុងការកសាងធនធានមនុស្សផ្នែកជំនាញបច្ចេកទេសធនាគារ សម្រាប់បម្រើការអភិវឌ្ឍនៃវិស័យធនាគារនៅកម្ពុជា ដោយសិស្ស-និស្សិតបញ្ចប់ការសិក្សាភាគច្រើនបានបម្រើការងារទាំងនៅធនាគារកណ្ដាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាក្រសួង-ស្ថាប័ន និងក្រុមហ៊ុនផ្សេងៗ។ បច្ចុប្បន្ន អគារសិក្សារបស់មណ្ឌលសិក្សាបច្ចេកទេសធនាគារក៏ត្រូវបានសាងសង់ឱ្យកាន់តែទំនើប និងធំទូលាយ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច និងស្តង់ដារនៃការអប់រំ។ នាពេលខាងមុខ មណ្ឌលសិក្សាបច្ចេកទេសធនាគារនឹងអាចប្រែក្លាយជាវិទ្យាស្ថាន ដែលផ្ដល់ការអប់រំកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ឬកម្រិតសមមូល ដើម្បីបន្តពង្រឹងសមត្ថភាពជំនាញក្នុងវិស័យធនាគារ ដែលឆ្លើយតបនឹងការរីកចម្រើននៃប្រព័ន្ធធនាគារ ក៏ដូចជាសមាហរណកម្មក្នុងតំបន់។ ក្នុងទិសដៅនេះ ខ្ញុំសូមស្នើឱ្យមណ្ឌលសិក្សាបច្ចេកទេសធនាគារត្រូវបន្តអភិវឌ្ឍកម្មវិធីសិក្សា លើកកម្ពស់គុណភាពសិក្សាស្រាវជ្រាវ និងបង្កើនទំនាក់ទំនងជាមួយបណ្ដាញគ្រឹះស្ថានអប់រំទាំងក្នុងនិងក្រៅប្រទេស។

១២/- ការងារសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា៖ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបានរួមចំណែកសម្រាលទុក្ខលំបាករបស់សមាជិក និងគ្រួសារសមាជិក ដោយបានពង្រឹងសាមគ្គីភាពនិងភាតរភាព ក្រោមយន្តការជួយគ្នាទៅវិញទៅមក។ ជាថ្មីម្ដងទៀត ខ្ញុំក៏សូមអបអរសាទរចំពោះការជ្រើសរើសប្រធាន និងគណៈដឹកនាំសមាគមថ្មី នៅក្នុងមហាសន្និបាតសមាគមបុគ្គលិកធនាគារជាតិនៃកម្ពុជា នាព្រឹកនេះ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា សមាគមបុគ្គលិកធនាគារជាតិនៃកម្ពុជា នឹង

បន្តបេសកកម្មរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ហើយក៏សូមស្នើឱ្យសមាគមបន្តយកចិត្តទុកដាក់ក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការផ្តល់ប្រាក់ឧបត្ថម្ភ ស្របតាមស្ថានភាពនិងតម្រូវការជាក់ស្តែង និងប្រើប្រាស់មូលនិធិរបស់សមាគមប្រកបដោយប្រសិទ្ធភាព និងចំគោលដៅ។ គួររំលេចថា មន្ត្រី-បុគ្គលិក និងសមាជិកគ្រួសារជាច្រើន បានស្ម័គ្រចិត្តទិញធានារ៉ាប់រងសុខភាពទៅតាមជម្រើសផ្សេងៗ ក្រោមការសម្របសម្រួលរបស់ធនាគារជាតិនៃកម្ពុជា ជាមួយក្រុមហ៊ុនធានារ៉ាប់រង។ ការទទួលសេវាធានារ៉ាប់រងនេះ ក៏បាននិងកំពុងបំពេញបន្ថែមលើយន្តការឧបត្ថម្ភរបស់សមាគម ជាពិសេសដើម្បីជួយសម្រាលការចំណាយលើការឈឺថ្កាត់ធ្ងន់ធ្ងរ។

១៣/- ការពង្រឹងតួនាទីរបស់សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន (ស.ស.រ)៖ សារមន្ទីរ ស.ស.រ បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ សេដ្ឋកិច្ច និងរូបិយវត្ថុ សម្រាប់សិស្សានុសិស្ស សាធារណជន និងភ្ញៀវទេសចរអន្តរជាតិ។ ខ្ញុំសូមស្នើឱ្យបន្តពង្រឹងការកែលម្អខ្លឹមសារនៃពិព័រណ៍ និងបង្កើតជាកម្មវិធីទស្សនារបស់សិស្ស និស្សិត ក្រោមការជួយឧបត្ថម្ភនានា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមជូនដំណឹងផងដែរថា ធនាគារជាតិនៃកម្ពុជាគ្រោងនឹងបើកដំណើរការសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុនៅខេត្តបាត់ដំបង និងមណ្ឌលពិព័រណ៍ពីព្រះរាជទស្សនកិច្ចរបស់ព្រះបាទស៊ីសុវត្ថិទៅកាន់ប្រទេសបារាំង នៅខេត្តកំពត នាឆ្នាំ២០២៥ខាងមុខ។

១៤/- ការផ្សព្វផ្សាយនិងទំនាក់ទំនង៖ នៅក្នុងសម័យដែលការទទួលបានព័ត៌មានមានភាពកាន់តែទូលំទូលាយនិងងាយស្រួល យើងម្នាក់ៗអាចរងគ្រោះឬបង្កគ្រោះ ដោយមិនដឹងខ្លួនពីការបំពុលព័ត៌មាន។ ទន្ទឹមនេះ យើងក៏អាចចូលរួមយ៉ាងសកម្មផងដែរក្នុងការពង្រឹងការយល់ដឹងរបស់សាធារណជន តាមរយៈការចូលរួមមានមតិនិងបកស្រាយទៅតាមជំនាញរបស់ខ្លួន ក្នុងករណីដែលមានព័ត៌មានមិនពិត ឬបោកប្រាស់ណាមួយកើតឡើងចំពោះធនាគារជាតិនៃកម្ពុជា។ ក្នុងន័យនេះ ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់ ប្រធាននាយកដ្ឋាននិងអង្គភាពក្រោមឱវាទ ដូចខាងក្រោម៖

i/- លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាឌីជីថលតាមរយៈការពង្រឹងសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងទូរគមនាគមន៍ ក៏ដូចជាឧបករណ៍ឌីជីថលនានា

ii/- ចែករំលែកនៅក្នុងបណ្តាញសង្គមនូវព័ត៌មានណាដែលមានផលប្រយោជន៍ ជាពិសេសពាក់ព័ន្ធនឹងវិស័យធនាគារ។ កន្លងមក ខ្ញុំសង្កេតឃើញថាមន្ត្រីបុគ្គលិកយើងមិនសូវមានការចែករំលែកពីព័ត៌មាននេះទេ ដែលទាមទារឱ្យមានការចូលរួមកាន់តែសកម្មបន្ថែមទៀត និង

iii/- រួមចំណែកការពារទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជាតាមរយៈការប្រើបណ្តាញសង្គម ដោយការទទួលខុសត្រូវ និងគ្រប់គ្រងទិន្នន័យឱ្យមានសុវត្ថិភាពជាដើម។ ទន្ទឹមនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាធនធានមនុស្ស ដើម្បីពង្រឹងការការពារសន្តិសុខសាយប័រ និងព័ត៌មានអតិថិជន។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំសូមស្នើឱ្យគ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទទាំងអស់ ត្រូវបន្តពង្រឹងវិន័យនិងបទបញ្ជាផ្ទៃក្នុងឱ្យបានខ្ជាប់ខ្ជួន ព្រមទាំងលើកកម្ពស់កិច្ចសហការល្អ សំដៅធានាឱ្យបាននូវគុណភាពនិងប្រសិទ្ធភាពការងារ។ គួរបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រី-បុគ្គលិក តាមរយៈការស្កេនមុខ (Face Attendance) ជាមួយនឹងឧបករណ៍ស្កេនមុខដែលបានបំពាក់នៅតាមច្រកចេញ-ចូលនៃអគារធនាគារជាតិនៃកម្ពុជាទាំងអស់ ត្រូវបានដាក់ឱ្យអនុវត្ត ចាប់តាំងពីដើមឆ្នាំ២០២៤នេះមក ក្នុងគោលដៅពង្រឹងវិន័យ សុវត្ថិភាព និងប្រសិទ្ធភាពការងាររបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងប្រើប្រាស់ជាមូលដ្ឋានក្នុងការវាយតម្លៃលក្ខណៈសម្បត្តិរបស់មន្ត្រី-បុគ្គលិកផងដែរ។

ជារួម ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតរបស់យើងពិតជាក្ដាប់បាននូវខ្លឹមសារសំខាន់ៗនៃលទ្ធផលនិងទិសដៅការងារ ដែលបានលើកឡើងក្នុងអង្គសន្និបាតយើង។ ខ្ញុំក៏សូមថ្លែងការកោតសរសើរដល់មន្ត្រីបុគ្គលិកយើង ដែលអនុវត្តភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានភាពជាម្ចាស់លើការងារ ព្រមទាំងបានរក្សាសាមគ្គីភាពជាប្រពៃណីក្នុងនាមជាសមាជិកគ្រួសារតែមួយ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តម ទេសាភិបាលកិត្តិយស ដែលបានខិតខំដឹកនាំធនាគារជាតិនៃកម្ពុជា និងរួមចំណែកកសាងសមិទ្ធផលជាច្រើនក្នុងប្រព័ន្ធធនាគារ ដោយបានឆ្លងកាត់ដំណាក់កាលលំបាកៗនិងវិបត្តិសកលជាច្រើន និងការផ្លាស់ប្តូរជាបន្តបន្ទាប់ រហូតមានការអភិវឌ្ឍរីកចម្រើនរឹងមាំ មកដល់បច្ចុប្បន្ននេះ។



ខ្ញុំសូមផ្ដាំផ្ញើដល់មន្ត្រីបុគ្គលិកយើងទាំងអស់ ដូចអ្វីដែល ឯកឧត្តម ទេសាភិបាលកិត្តិយស តែងតែរំលឹកជាស់តឿនជារឿយៗ ឱ្យបន្តដុះខាត់ចំណេះដឹងនិងសមត្ថភាពជាប់ជាប្រចាំ ព្រមទាំងខិតខំបំពេញមុខងារនិង

ភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មានភាពស្មោះត្រង់ និងមានសាមគ្គីភាពល្អប្រសើរ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មន្ត្រី-បុគ្គលិកយើងគ្រប់លំដាប់ថ្នាក់ នឹងបន្តរួមចំណែកសម្រេចបានសមិទ្ធផលថ្មីៗ បន្ថែមទៀតសម្រាប់ការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការរីកចម្រើននៃប្រព័ន្ធធនាគារនៅកម្ពុជា ប្រកបដោយភាពរឹងមាំ និងបរិយាបន្ន ដែលផ្តល់ជាបរិស្ថានអំណោយផលដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់ នៅក្នុងឆ្នាំថ្មី២០២៤នេះ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាត សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងជាស្ថាពរ។

**សូមអរគុណ!**

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសិក្ខាសាលាស្តីពី ការអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ
# ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ជាមួយក្រសួងអប់រំ យុវជន និងកីឡា
# ដំណាក់កាលទី៣

ថ្ងៃព្រហស្បតិ៍ ៧រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤

សូមគោរព៖

- លោកជំទាវ គីម សេដ្ឋានី រដ្ឋលេខាធិការប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- លោកជំទាវ គ្រី ណាល់លីស រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី
- ឯកឧត្តម ស៊ូ សុជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា
- ឯកឧត្តម ប៊ូ ច័ន្ទភីរូ អគ្គនាយកនិយ័តករធានារ៉ាប់រងកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!





ថ្ងៃនេះជាទិវាដ៏ មហោឡារិក និងប្រកបដោយសេចក្តីសោមនស្សយ៉ាងក្រៃលែង ដែលធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមរៀបចំសិក្ខាសាលាស្តីពី ការអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ជាមួយក្រសួងអប់រំ យុវជន និងកីឡា "ដំណាក់កាលទី៣"។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធានារ៉ាប់រងកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងសមាគមទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នាពេលនេះ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង-ស្ថាប័ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បណ្តាដៃគូអភិវឌ្ឍន៍នានា និងភាគីពាក់ព័ន្ធទាំងអស់ ដែលកន្លងមកបានគាំទ្រយ៉ាងសកម្ម និងសហការយ៉ាងជិតស្និទ្ធ ជាមួយធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំកម្មវិធីនានា ជាពិសេស ការចូលរួមផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សាធារណជនគ្រប់មជ្ឈដ្ឋាន ក្នុងគោលដៅបណ្តុះចំណេះដឹងផ្នែកហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយថែមទៀត។




**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ចំណេះដឹងផ្នែកហិរញ្ញវត្ថុ គឺជាជំនាញដែលប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ ហើយក្នុងបរិបទដែលសេដ្ឋកិច្ចកំពុងវិវត្តជាប្រចាំ ការផ្តល់ឱ្យសិស្សានុសិស្សនូវជំនាញហិរញ្ញវត្ថុ ដូចជា ការយល់ដឹងអំពីប្រាក់ ការវិនិយោគ និងការចាត់ចែងហិរញ្ញវត្ថុចាប់ពីវ័យកុមារជាការងារចាំបាច់ដើម្បីឱ្យសិស្សានុសិស្សមានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តត្រឹមត្រូវក្នុងការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់អនាគតហិរញ្ញវត្ថុរបស់ពួកគេ។ កង្វះចំណេះដឹងផ្នែកហិរញ្ញវត្ថុអាចធ្វើឱ្យសិស្សានុសិស្ស ឬយុវជនអាចប្រឈមមុខនឹងបញ្ហាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ ដូចជា ធ្លាក់ក្នុងស្ថានភាពមានបំណុល ឬការវិនិយោគមិនល្អ ដែលបណ្តាលមកពីការសម្រេចចិត្តមិនត្រឹមត្រូវ។ លើសពីនេះ ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅជាវិធីសាស្ត្ររួមដែលនឹងជួយបណ្តុះស្មារតីនៃការទទួលខុសត្រូវ ការគិតពិចារណា និងជំនាញដោះស្រាយបញ្ហាដែលជាគុណសម្បត្តិដ៏មានតម្លៃសម្រាប់ភាពជោគជ័យសម្រាប់បុគ្គលម្នាក់ៗ។ ម៉្យាងទៀត ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ គឺជាការវិនិយោគនាពេលអនាគត ព្រោះវាមិនត្រឹមតែជួយបុគ្គលក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកដល់សុខុមាលភាព និងស្ថិរភាពនៃសង្គមរបស់យើងផងដែរ។

ក្នុងពិធីដ៏មហោឡារិកនេះ ខ្ញុំសូមគោរពអនុញ្ញាតជម្រាបជូនសិក្ខាសាលាទាំងមូល អំពីវឌ្ឍនភាពសំខាន់ៗនៃការអនុវត្តកន្លងមក និងការត្រៀមអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដូចតទៅ៖

ការពិភាក្សាលើគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ បានធ្វើឡើងជាបន្តបន្ទាប់រវាងក្រុមការងាររបស់ធនាគារជាតិនៃកម្ពុជានិងក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា តាំងពីឆ្នាំ២០១៧ ដោយបានឯកភាពគ្នាជារួមលើការកំណត់គោលដៅរយៈពេលវែងដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅចាប់ពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី១២ ជាពិសេសលើមុខវិជ្ជាពាក់ព័ន្ធនឹងរូបិយវត្ថុ ផែនការនិងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងហានិភ័យ។ ផ្អែកលើធនធានដែលយើងមាន ជាពិសេស ធនធានហិរញ្ញវត្ថុ ក្រុមការងារទាំងពីរបានឯកភាពបែងចែងការអនុវត្តគម្រោងជាបីដំណាក់កាល។ "ដំណាក់កាលទី១" បានចាប់ផ្តើមជាផ្លូវការក្នុងឆ្នាំ២០១៧ គឺជាដំណាក់កាលពិនិត្យជារួម លើលទ្ធភាពបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ក្នុងនោះក៏រួមបញ្ចូលនូវការវាយតម្លៃរបស់អ្នកជំនាញអប់រំហិរញ្ញវត្ថុ ការប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធសំខាន់ ដូចជា មន្ត្រី និងលោកគ្រូ អ្នកគ្រូ លើមុខវិជ្ជាទាំងអស់ក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តទាំងសាលារៀនសាធារណៈនិងឯកជន។ ការអនុវត្តការងារក្នុងដំណាក់កាលទី១ នេះ ទទួលបានជោគជ័យដោយភាគីទាំងពីររៀបចំបានជារបាយការណ៍វាយតម្លៃរួមមួយ និងជាពិសេសកំណត់បាននូវមុខវិជ្ជាដែលត្រូវបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងផែនការសម្រាប់ដំណាក់កាលជាបន្តបន្ទាប់។




"ដំណាក់កាលទី២" បានចាប់ផ្តើមនៅក្នុងខែធ្នូ ឆ្នាំ២០១៩ បន្ទាប់ពីភាគីទាំងពីរបានចុះអនុស្សរណៈនៃការយោគយល់គ្នាលើកទី១ រួចមក។ ក្នុងដំណាក់កាលនេះ មានមុខវិជ្ជាពាក់ព័ន្ធសម្រាប់ថ្នាក់ទី៤ លើមុខវិជ្ជាគណិតវិទ្យា បំណិនជីវិតតាមមូលដ្ឋាន និងសិក្សាសង្គម និងថ្នាក់ទី៧ លើមុខវិជ្ជាគណិតវិទ្យា បំណិនជីវិតតាមមូលដ្ឋាន គេហសេដ្ឋកិច្ចវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា។ ការងារគន្លឹះក្នុងដំណាក់កាលនេះរួមមាន៖

**១/. ការរៀបចំសៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្ស**

សៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្សក៏ត្រូវបានរៀបចំដោយបានបញ្ចូលនូវប្រធានបទដែលពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងមុខវិជ្ជាសិក្សាសម្រាប់ថ្នាក់ទី៤ និងថ្នាក់ទី៧។

សៀវភៅណែនាំសម្រាប់គ្រូត្រូវបានរៀបចំដោយបន្ថែមលក្ខណៈបីយ៉ាង រួមមាន ការបញ្ចូលផែនការមេរៀននីមួយៗដែលជាទម្រង់កិច្ចតែងការបង្រៀនស្របតាមបរិបទរបស់កម្ពុជា ការរៀបចំចម្លើយសម្រាប់គ្រូបង្រៀនលើសំណួរនិងសកម្មភាពសម្រាប់ឱ្យសិស្សអនុវត្ត និងការពិភាក្សាដែលអាចឱ្យគ្រូបង្រៀនបញ្ជ្រាបនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងពេលបង្រៀនបាន។

សៀវភៅមេរៀនសម្រាប់សិស្សត្រូវបានរៀបចំដោយបញ្ចូលនូវព័ត៌មានលម្អិតសំខាន់ៗពីចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅលើប្រធានបទជាក់លាក់ ជាពិសេសបានបញ្ចូលនូវសំណួររំលឹកមេរៀននៅរាល់ចុងបញ្ចប់នៃមេរៀននីមួយៗ ដើម្បីទាញការចាប់អារម្មណ៍របស់សិស្សលើខ្លឹមសារមេរៀននិងអាចផ្លាស់ប្តូរអាកប្បកិរិយាទៅតាមប្រធានបទដែលបានសិក្សា។

**២/. ការបណ្តុះបណ្តាលគ្រូបង្គោល**

ការបណ្តុះបណ្តាលគ្រូបង្គោលត្រូវបានធ្វើឡើងក្នុងគោលបំណងកសាងសមត្ថភាពនិងទំនុកចិត្តរបស់គ្រូបង្គោលក្នុងការបង្រៀនមេរៀនដែលពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ កសាងការយល់ដឹងរបស់គ្រូបង្គោលអំពីគរុកោសល្យនៃការបង្រៀន និងទទួលមតិកែលម្អលើខ្លឹមសារសៀវភៅ។ ការបណ្តុះបណ្តាលនេះមានគ្រូបង្គោលមកពីអនុវិទ្យាល័យ និងសាលាបឋមសិក្សានៃខេត្តកំពង់ចាម ខេត្តកំពត និងខេត្តសៀមរាប ចំនួន ២១ រូប។

ការបណ្តុះបណ្តាលផ្តោតលើប្រធានបទសំខាន់ៗទាក់ទងនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ រួមមាន លុយ ផែនការនិងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ មូលដ្ឋាននៃការអប់រំផ្នែកហិរញ្ញវត្ថុផ្តោតលើចំណូល ចំណាយ និងសន្សំ ការទទួលខុសត្រូវហិរញ្ញវត្ថុផ្តោតលើការខ្ចីនិងការគ្រប់គ្រងបំណុល ព្រមទាំងតួនាទីនិងការទទួលខុសត្រូវរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអតិថិជន វិធីសាស្ត្រវាយតម្លៃកម្រិតនៃការយល់ដឹងរបស់សិស្ស គរុកោសល្យក្នុងការបង្រៀនផ្តោតលើទម្រង់និងកិច្ចតែងការបង្រៀន វិធីសាស្ត្របង្រៀន និងវិធីសាស្ត្របង្រៀនតាម Bloom's Taxonomy ដែលបង្រៀនសិស្សឱ្យអនុវត្តសកម្មភាពសំខាន់ៗចំនួន ៦ គឺ ចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើត។

**៣/. ការបង្រៀនសាកល្បង**

ការបង្រៀនសាកល្បងដែលមានរយៈពេល ៦ សប្តាហ៍ ត្រូវបានធ្វើឡើងនៅសាលារៀនចំនួន ៦ ក្នុងនោះមានសាលាបឋមសិក្សាចំនួន ៣ និងអនុវិទ្យាល័យចំនួន ៣ នៅក្នុងខេត្តចំនួន ៣ គឺខេត្តកំពត ខេត្តកំពង់ចាម និងខេត្តសៀមរាបលើថ្នាក់ទី៤ ចំនួន ២ មុខវិជ្ជា គឺ បំណិនជីវិតតាមមូលដ្ឋាន និងសិក្សាសង្គម និងថ្នាក់ទី៧ ចំនួន ២ មុខវិជ្ជា គឺ បំណិនជីវិតតាមមូលដ្ឋាន និងគណិតវិទ្យា។

**៤/. ការកែសម្រួលសៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្ស**

ឯកសារជាសៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្ស សម្រាប់ថ្នាក់ទី៤ និងទី៧ ត្រូវបានកែលម្អដោយផ្អែកលើមតិយោបល់ និងធាតុចូលលើខ្លឹមសារមេរៀន រូបភាព និងទម្រង់នៃការសរសេរ ដែលទទួលបានក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលនេះ និងការបង្រៀនសាកល្បងនៅតាមសាលារៀនជាក់ស្តែង ដែលបានជ្រើសរើស។

**៥/. ការបោះពុម្ព**

ឯកសារជាសៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្ស សម្រាប់ថ្នាក់ទី៤ និងទី៧ ត្រូវបានបញ្ចប់និងមានចុះហត្ថលេខាពីថ្នាក់ដឹកនាំស្ថាប័នទាំង ២ ឯការបោះពុម្ពសៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្សជាបឋមក៏បានបញ្ចប់រួចរាល់ហើយដែរ។

ជារួម ការអនុវត្តគម្រោងមានការអូសបន្លាយពេលវេលា ដោយការរីករាលដាលនៃជំងឺកូវីដ១៩ ដែលធ្វើឱ្យផ្នែកខ្លះនៃគម្រោងមិនអាចអនុវត្តបានទាន់ពេលវេលា ជាពិសេស គឺការបង្រៀនសាកល្បង។ ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ជំនួយបច្ចេកទេសដល់ការអនុវត្តគម្រោងខាងលើទាំងដំណាក់កាលទី១ និងដំណាក់កាលទី២។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ពេលនេះ ការអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅបានឈានដល់ "ដំណាក់កាលទី៣" ដែលជាដំណាក់កាលចុងក្រោយ ហើយជាការងារដែលមានទ្រង់ទ្រាយធំនិងមានរយៈពេលបីឆ្នាំ គឺចាប់ផ្តើមពីឆ្នាំ២០២៤ រហូតដល់ឆ្នាំ២០២៦។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ពិតជាត្រូវការនូវការគាំទ្រ ក៏ដូចជាការចូលរួមកាន់តែសកម្មថែមទៀតពីសំណាក់ក្រសួង-ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធានារ៉ាប់រងកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងសមាគមទាំងអស់ ដើម្បីសម្រេចបាននូវផែនការសកម្មភាពទាំងឡាយក្នុងដំណាក់កាលទី៣ នេះ ដែលការងារជាអាទិភាពជាគន្លឹះគឺការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ថ្នាក់ចំនួន ៧ ដែលនៅសល់ (ថ្នាក់ទី៥, ៦, ៨, ៩, ១០, ១១ និង ១២) ការបណ្តុះបណ្តាលគ្រូបង្គោល និងធ្វើតេស្តសាកល្បងនៅតាមសាលារៀនជាក់ស្តែង។ ការអនុវត្តគម្រោងនេះត្រូវធ្វើឡើងរយៈពេល ៣ឆ្នាំ ដោយឆ្នាំ២០២៤ (ថ្នាក់ទី៥, ៨ និង ១១) ឆ្នាំ២០២៥ (ថ្នាក់ទី៦, ៩ និង ១២) និងឆ្នាំ២០២៦ (ថ្នាក់ទី១០ និងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានចំពោះគ្រប់ថ្នាក់)។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ការជួបជុំថ្ងៃនេះ គឺជាពិធីដ៏វិសេសវិសាលមួយ ដើម្បីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាលើកទី២ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា សំដៅបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ "ដំណាក់កាលទី៣" ព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការផ្សេងៗទៀត រួមទាំងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថលផងដែរ។ ភាពជាដៃគូនេះបង្ហាញនូវការប្តេជ្ញាចិត្តរួមគ្នា និង

ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីបណ្តុះជំនាញហិរញ្ញវត្ថុសំខាន់ៗ ជួយដល់សិស្សានុសិស្សក្នុងការសម្រេចចិត្តត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ។

មុននឹងបញ្ចប់ ជាថ្មីម្តងទៀត ខ្ញុំសូមសំដែងនូវការគោរពនិងអំណរគុណយ៉ាងជ្រាលជ្រៅជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងថ្នាក់ដឹកនាំរបស់ក្រសួងទាំងអស់ ចំពោះការគាំទ្រ និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា។

ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះតំណាងដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ដែលផ្តល់នូវកិច្ចសហការ និងការឧបត្ថម្ភ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងសូមសំដែងនូវការកោតសរសើរចំពោះក្រុមការងាររបស់ធនាគារជាតិនៃកម្ពុជា និងក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានបំពេញការងារបានយ៉ាងល្អ ប្រកបដោយការទទួលខុសត្រូវ ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ចំពោះការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជា។

**សូមអរគុណ!**



# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១៣
# នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៤

ថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤

**សូមគោរព៖**

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**



ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានមកចូលរួមក្នុងពិធី អបអរសាទរខួបអនុស្សាវរីយ៍ លើកទី១១៣នៃទិវាអន្តរជាតិនារី ៨មីនាឆ្នាំ២០២៤សម្រាប់ មន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា។ ការប្រារព្ធពិធី ខួបអនុស្សាវរីយ៍នេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ និងបានផ្តល់ឱកាសដល់មន្ត្រីបុគ្គលិកយើងទាំងអស់បាន ជួបជុំសំណេះសំណាលគ្នា ក៏ដូចជាចូលរួមអបអរសាទរ ទិវាអន្តរជាតិនារី ៨ មីនា ព្រមទាំងដើម្បីលើកកម្ពស់ និង ថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកជានារីនៅធនាគារជាតិនៃកម្ពុជា ដែលបានរួមចំណែកកសាង និងអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។

ឆ្នាំនេះ យើងប្រារព្ធពិធីនេះឡើងក្រោមប្រធានបទ **“ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល”** ក្នុង គោលបំណងរំលេចសក្តានុពល និងភាពចាំបាច់នៃការលើកកម្ពស់ការចូលរួម និងភាពជាតំណាង របស់ស្ត្រី និងក្មេងស្រីក្នុងយុគសម័យឌីជីថលប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ ការណ៍នេះធានាបាននូវសិទ្ធិ និងឱកាសពេញលេញក្នុងការទទួលបានជម្រើស និងភាពជាតំណាង ប្រកបដោយសក្តានុពល ក្នុងការចូលរួម ចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិប្រកបដោយចីរភាព និងបរិយាបន្ន។

ខ្ញុំសូមគាំទ្រប្រធានបទយើងឆ្នាំនេះ ដែលផ្តោតជាសំខាន់ទៅលើការចូលរួមរបស់ ស្ត្រី និងយុវនារី ក៏ដូចជាបុរស និងយុវជន ក្នុងយុគសម័យឌីជីថល ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិទាំងមូល ស្របតាម លទ្ធិប្រជាធិបតេយ្យរបស់ប្រទេស។ ជាមួយគ្នានេះ ខ្ញុំសូមលើកទឹកចិត្តឱ្យស្ត្រី និងបុរសមានសិទ្ធិនិងឱកាសដូចគ្នា ក្នុងការទទួលបាននូវចំណេះដឹង និងជំនាញបច្ចេកទេសគ្រប់ផ្នែក និងចូលរួមគ្រប់វិស័យ ដែលបច្ចុប្បន្នស្ត្រី

បានជួយរំលែកបន្ទុកគ្រួសារ សង្គម និងរួមចំណែក កសាង និងអភិវឌ្ឍប្រទេសជាតិ ជាពិសេស ចំពោះការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត ផ្នែកនយោបាយ ការងារសង្គម និងសេដ្ឋកិច្ច ដោយសារស្ត្រីមានប្រាជ្ញាស្មារតីតស៊ូអត់ធ្មត់ ដើម្បីការរក្សាសុខសន្តិភាព និងការអភិវឌ្ឍនៅគ្រប់កាលៈទេសៈទាំងអស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ចំពោះប្រព័ន្ធធនាគារទាំងមូល ធនាគារជាតិនៃកម្ពុជាក៏មានយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការចូលរួមសកម្មភាពផ្សេងៗ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា ជានិច្ចជាកាលតែងតែសហការជាមួយនឹងក្រសួងពាក់ព័ន្ធក្នុងការគាំទ្រ និងបង្កើតកម្មវិធីជាច្រើនសម្រាប់លើកកម្ពស់ស្ត្រី ព្រមទាំងដើម្បីរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានដាក់ចេញ ដោយរួមមានការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ ការបញ្ចូលអក្ខរកម្មហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅ និងការលើកទឹកចិត្តឱ្យប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលជាដើម។ ជាមួយគ្នានេះ គិតត្រឹមខែមករា ឆ្នាំ២០២៤ ចំនួនអ្នកខ្ចីពីគ្រឹះស្ថានធនាគារ មានប្រមាណ ៦០% ជាស្ត្រី និងចំនួនអ្នកខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានប្រមាណ ៦៥% ជាស្ត្រី ខណៈចំនួនអ្នកដាក់ប្រាក់បញ្ញើក្នុងគ្រឹះស្ថានធនាគារមានប្រមាណ ៤៥% ជាស្ត្រី និងចំនួនអ្នកដាក់ប្រាក់បញ្ញើក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៦៨%។ ទាំងនេះ បង្ហាញពីសមាមាត្រដែលស្ត្រីបានចូលរួមទទួល និងប្រើប្រាស់សេវាហិរញ្ញវត្ថុប្រហាក់ប្រហែលនឹងបុរស។





**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នៅក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលមានគោលនយោបាយ និងយុទ្ធសាស្ត្រ ផ្តោតយ៉ាងជាក់លាក់ទៅលើការលើកកម្ពស់ សមភាពយេនឌ័រ និងការអភិវឌ្ឍធនធានមនុស្ស ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ប្រទេសឱ្យឈានឆ្ពោះទៅរកភាពចម្រើនរុងរឿង។ ទន្ទឹមនេះ ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមាន **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាព្រះប្រធានកិត្តិយស និងគណៈកម្មាធិការជាតិ

លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលមាន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ជាប្រធានកិត្តិយស ក៏ជាចំណែកមួយក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី តម្លៃស្ត្រី រួមទាំងសីលធម៌សង្គម ប្រពៃណី និងវប្បធម៌ដ៏ល្អផូរផង់របស់កម្ពុជាផងដែរ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងកោតសរសើរខ្លាំងចំពោះថ្នាក់ដឹកនាំនារី និងមន្ត្រី-បុគ្គលិកនារីធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងខិតខំប្រឹងប្រែងក្នុងការជំរុញការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងយុគសម័យបរិវត្តកម្មឌីជីថល។ ការណ៍នេះ ក៏បានបង្ហាញថាស្ត្រីត្រូវបានចាត់ទុកជាដៃគូដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងគ្រួសារ តាមរយៈការជួយជំរុញការកសាងនិងការអភិវឌ្ឍសមត្ថភាពស្ត្រី ក៏ដូចជាការផ្ដល់ឱកាសឱ្យស្ត្រីចូលរួមប្រកបដោយសមធម៌ក្នុងគ្រប់ការងារនិងក្នុងគ្រប់វិស័យ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្ដី ចំពោះថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកនារី ធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស សូមបានប្រកបតែនឹងសេចក្ដីសុខ សេចក្ដីចម្រើន គ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងកម្មវិធីថ្ងៃនេះ និងសូមជូនពរឱ្យជួបប្រទះ តែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**



# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសខួបលើកទី៤៤ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ៖
# ដំណើរឆ្ពោះទៅមុខនៃប្រាក់រៀល និងប្រព័ន្ធបាគង

ថ្ងៃពុធ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

**សូមគោរព៖**

**- គណៈអធិបតី ជាទីគោរព!**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**



ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ២០ មីនា ១៩៨០ - ២០ មីនា ២០២៤។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាតំណាងក្រសួង-ស្ថាប័ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុន-សហគ្រាស គ្រឹះស្ថានឧត្តមសិក្សា និងប្អូនៗនិស្សិតទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងសិក្ខាសាលានាពេលនេះ។ វត្តមានរបស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងប្អូនៗទាំងអស់ ពិតជាបង្ហាញការយកចិត្តទុកដាក់លើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់យើងទាំងអស់គ្នា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពីប្រវត្តិនៃប្រាក់រៀល ដែលបានឆ្លងកាត់នូវសម័យកាលជាច្រើន មុននឹងមានស្ថិរភាពល្អប្រសើរដូចបច្ចុប្បន្ន។ បន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យពីបារាំង ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូងនៅខែធ្នូ ឆ្នាំ១៩៥៤ និងបានបោះផ្សាយប្រាក់រៀលសម្រាប់ប្រើប្រាស់នៅក្នុងប្រទេស នៅខែកញ្ញា ឆ្នាំ១៩៥៥ ក្នុងសម័យសង្គមរាស្ត្រនិយម។ ប៉ុន្តែគួរឱ្យសោកស្តាយប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលចាប់តាំងពីដើមឆ្នាំ១៩៧០មក ដែលបានបណ្តាលឱ្យជំនឿទុកចិត្តលើប្រាក់រៀលចាប់ផ្តើមបាត់បង់ ហើយនៅក្នុងរបប ប៉ុល ពត ប្រាក់រៀលត្រូវបានបំបាត់ឈប់ឱ្យប្រើប្រាស់ទាំងស្រុង។ ក្រោយរបបខ្មែរក្រហម ប្រាក់រៀលត្រូវបានបោះផ្សាយឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០

នៅក្នុងសម័យកាលមួយដែលសេដ្ឋកិច្ចជាតិមានសភាពទន់ខ្សោយ ជាមួយនឹងការបាត់បង់ទំនុកចិត្តលើប្រាក់រៀល។ សង្គ្រាមស៊ីវិលបានអូសបន្លាយរហូតដល់ចុងឆ្នាំ១៩៩៨ ដែលធ្វើឱ្យការស្តារជំនឿទុកចិត្តលើប្រាក់រៀលឡើងវិញជាការងារដ៏លំបាកបំផុត បើទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានខិតខំពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិយ៉ាងណាក៏ដោយ។

ក្រោយកម្ពុជាទទួលបានសុខសន្តិភាពពេញលេញនៅចុងឆ្នាំ១៩៩៨ ក្រោមនយោបាយឈ្នះ-ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានមានលំនឹងឡើងវិញប្រកបដោយទំនុកចិត្ត តែកម្រិតដុល្លារូបនីយកម្មបានកើនឡើងរហូតដល់កម្រិតជាង ៦០% នាចុងទសវត្សរ៍ឆ្នាំ១៩៩០ និងដល់ប្រមាណ ៨០% នាចុងទសវត្សរ៍ឆ្នាំ២០០០។ ស្ថិរភាពនយោបាយនិងសេដ្ឋកិច្ចបានបើកលទ្ធភាពឱ្យរាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាដាក់ចេញនូវនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាបន្តបន្ទាប់ តាមរយៈយន្តការទីផ្សារ ដោយបានស្តារទំនុកចិត្តលើប្រាក់រៀល និងបង្កើតឧបករណ៍រូបិយវត្ថុជាប្រាក់រៀល។ ជាលទ្ធផល ទំហំប្រាក់រៀលក្នុងចរាចរណ៍បានកើនឡើងជាលំដាប់ ជាមធ្យម ១៥% ក្នុង១ឆ្នាំ នាអំឡុង២ទសវត្សរ៍ចុងក្រោយ ខណៈដែលឥណទាននិងប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារជារៀល ក៏បានកើនឡើងលឿនក្នុងអត្រា ៣៥% និង ៣០% រៀងគ្នា។







ទោះយ៉ាងណា កិច្ចខិតខំប្រឹងប្រែងកន្លងមក បានត្រឹមតែទប់ស្កាត់ដុល្លាររូបនីយកម្មមិនឱ្យកើនឡើងតទៀត ប៉ុន្តែមិនទាន់អាចបន្ថយកម្រិតដុល្លាររូបនីយកម្មនៅឡើយទេ។ នៅត្រង់ចំណុចនេះ មេរៀនប្រវត្តិសាស្ត្របានបង្ហាញថាការបាត់បង់ទំនុកចិត្តលើប្រាក់រៀលអាចកើតឡើងក្នុងរយៈពេលដ៏ខ្លី តែការស្តារទំនុកចិត្តឡើងវិញគឺជាការលំបាក ហើយទាមទារនូវពេលវេលានិងការចូលរួមយ៉ាងសកម្មរបស់ក្រសួង-ស្ថាប័នសាធារណៈ ក្រុមហ៊ុន-សហគ្រាស ប្រជាជនទូទៅ និងភាគីពាក់ព័ន្ធទាំងអស់។ ម៉្យាងទៀត ឆ្លងកាត់ការជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ចធំៗកន្លងមក បានបង្ហាញថាកម្ពុជាត្រូវការពង្រឹងការប្រើប្រាស់ប្រាក់រៀល ដែលអាចរួមចំណែកជួយការពារ ក៏ដូចជាស្តារសេដ្ឋកិច្ចពីវិបត្តិ ដោយហេតុថា ការប្រើប្រាស់ប្រាក់រៀលទូលំទូលាយនឹងជួយឱ្យកម្ពុជាមានអធិបតេយ្យនិងឯករាជ្យក្នុងការអនុវត្តនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេសនយោបាយរូបិយវត្ថុ ដែលអាចជួយដល់ការជំរុញការវិនិយោគនិងការប្រើប្រាស់ក្នុងស្រុកតាមរយៈការជួយបន្ថយ ឬបង្កើនអត្រាការប្រាក់នៅលើទីផ្សារ និងការបញ្ចេញសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ច។ ដូចដែលប្រទេសមួយចំនួនធំបានអនុវត្តក្នុងវិបត្តិហិរញ្ញវត្ថុសកលនិងវិបត្តិកូវីដ-១៩ ធនាគារកណ្តាលបានបន្ទាបអត្រាការប្រាក់គោល ដើម្បីបន្ថយអត្រាការប្រាក់នៅលើទីផ្សារ និងបានចាក់បញ្ចូលសាច់ប្រាក់បន្ថែមដល់សេដ្ឋកិច្ច ក្នុងគោលដៅជំរុញសកម្មភាពសេដ្ឋកិច្ច។ ជាថ្មីម្តងទៀត ការធ្វើដូច្នេះបានទាល់តែធនាគារកណ្តាលអាចគ្រប់គ្រងការប្រើប្រាស់នយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព គឺនៅពេលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្នុងទិសដៅលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានខិតខំសម្រួលការប្រើប្រាស់ប្រាក់រៀលឱ្យមានភាពងាយស្រួលជាបន្តបន្ទាប់។ ក្នុងចំណោមវិធានការនានា ប្រព័ន្ធទូទាត់អេឡិចត្រូនិកជាពិសេសប្រព័ន្ធបាគង បានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រួលដល់ការទូទាត់ប្រាក់រៀលឱ្យកាន់តែមានភាពទាន់សម័យ ឆាប់រហ័ស និងចំណាយតិច។ ជាលទ្ធផល ការប្រើប្រាស់ប្រាក់រៀលតាមប្រព័ន្ធអេឡិចត្រូនិកបានកើនឡើង ក្នុងអត្រាមួយខ្ពស់ ដោយក្នុងឆ្នាំ២០២៣ ប្រតិបត្តិការទូទាត់ជាប្រាក់រៀលតាមប្រព័ន្ធអេឡិចត្រូនិកបានកើនឡើង ៤៤% ធៀបនឹងឆ្នាំ២០២២ និងខ្ពស់ជាងកំណើននៃប្រតិបត្តិការទូទាត់អេឡិចត្រូនិកជាប្រាក់ដុល្លារអាមេរិក ដែលកើនក្នុងអត្រា ៣,១%។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានជំរុញការតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសជិតខាងនិងក្នុងតំបន់ ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជា ដែលមានគណនីជាប្រាក់រៀលអាចទូទាត់តាមប្រព័ន្ធយូអរកូដ (QR code) បានងាយស្រួលនៅក្នុងប្រទេសទាំងនោះ។ ការតភ្ជាប់នេះក៏បានអនុញ្ញាតឱ្យទេសចរបរទេសអាចទូទាត់តាមរយៈយូអរកូដ (QR code) នៅតាមហាងទំនិញនានានៅកម្ពុជា ដែលហាងទាំងនោះនឹងទទួលបានការទូទាត់នេះជាប្រាក់រៀល។ បច្ចុប្បន្ន កម្ពុជាបានតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយប្រទេសថៃ វៀតណាម និងឡាវ ព្រមទាំងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិមួយចំនួន ជាមួយនឹងផែនការតភ្ជាប់ជាមួយប្រទេសផ្សេងទៀតក្នុងតំបន់ ដូចជា ចិន និងឥណ្ឌា ជាដើម។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានជំរុញការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ តាមរយៈការដាក់ចេញបទប្បញ្ញត្តិ ដែលមានលក្ខណៈអំណោយផលដល់ការប្រើប្រាស់ប្រាក់រៀល រួមមាន ការយកកម្រៃសេវាលើប្រតិបត្តិការជាប្រាក់រៀលទាបជាងរូបិយប័ណ្ណបរទេស ការតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានឥណទានជាប្រាក់រៀលយ៉ាងតិច ១០% នៃឥណទានសរុប និងវិធានការមួយចំនួនផ្សេងទៀត ដូចជាការបញ្ចេញសន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និងការសម្រួលដល់ការគ្រប់គ្រងសន្ទនីយភាពជាប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ ដែលទាំងអស់នេះបានជួយកាត់បន្ថយថ្លៃដើម និងសម្រួលដល់ប្រតិបត្តិការជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងជាប្រចាំក្នុងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនពីសារៈសំខាន់នៃប្រាក់រៀល។ យើងបានបង្កើតឱ្យមានសារមន្ទីរព្រះស្រីឦសានវរ្ម័ន (ស.ស.រ) ដែលនៅទីនោះមានការអត្ថាធិប្បាយយ៉ាងក្បោះក្បាយអំពីទំនាក់ទំនងរវាងរូបិយវត្ថុជាមួយស្ថាប័ននិងសង្គម និងប្រវត្តិសេដ្ឋកិច្ច-នយោបាយនៅកម្ពុជាក្នុងអំឡុងជាងពីរពាន់ឆ្នាំមកនេះ។ ខ្ញុំក៏សូមលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័ន គ្រឹះស្ថានសិក្សា ក្រុមហ៊ុន-សហគ្រាស និងសាធារណជនចូលរួមទស្សនាស្វែងយល់ពីប្រវត្តិរូបិយវត្ថុនិងសេដ្ឋកិច្ចរបស់កម្ពុជានៅសារមន្ទីរ ស.ស.រ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំសិក្ខាសាលានិងកម្មវិធីផ្សព្វផ្សាយពីប្រាក់រៀលនៅតាមបណ្តាខេត្ត ដើម្បីបញ្ជ្រាបស្មារតីស្រឡាញ់ប្រាក់រៀល និងលើកកម្ពស់ការចូលរួមរបស់សាធារណជនឱ្យងាកមកប្រើប្រាស់រូបិយវត្ថុជាតិឱ្យកាន់តែច្រើនជាងមុន។ នាថ្ងៃអាទិត្យ ទី២៤ ខែមីនា ខាងមុខ យើងនឹងរៀបចំកម្មវិធីផ្សព្វផ្សាយប្រាក់រៀល និងប្រព័ន្ធបាគងនៅផ្សារទំនើប K Mall ដោយមានការចូលរួមពីតារាចម្រៀងល្បីៗរបស់ព្រះរាជាណាចក្រកម្ពុជា រួមមានកញ្ញា មាស សុខសោភា លោក ម៉ម ពេជ្ជរិទ្ធ និងកញ្ញា រ៉ូលីន និងកម្មវិធីនឹងចាប់ផ្តើមពីម៉ោង ១០ព្រឹក ដល់ម៉ោង ៨:៣០ល្ងាច។

គួររំលេចផងដែរថា ការសម្រេចឱ្យអនុវត្តវិធានការនានាក្នុងការលើកកម្ពស់ប្រាក់រៀលត្រូវបានសិក្សាយ៉ាងល្អិតល្អន់ ផ្អែកលើការស្រាវជ្រាវនិងទិន្នន័យយ៉ាងច្បាស់លាស់។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានចូលរួមសិក្សាស្រាវជ្រាវជាមួយស្ថាប័នអន្តរជាតិ ដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA និងមូលនិធិរូបិយវត្ថុអន្តរជាតិ IMF ទៅលើយុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ កាលពីខែវិច្ឆិកា





ឆ្នាំ២០២៣ កន្លងទៅ សៀវភៅស្ដីពី "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច" ត្រូវបានផ្សព្វផ្សាយជាសាធារណៈ សម្រាប់ផ្ដល់ជាធាតុចូលដល់គោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP Cambodia) ក្នុងការសិក្សាស្រាវជ្រាវលើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងការទូទាត់ប្រាក់ឈ្នួលនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ស្បែកជើង និងទំនិញធ្វើដំណើរ។ ការស្រាវជ្រាវបានរកឃើញថា កម្មករមានចំណូលជាប្រាក់ដុល្លារអាមេរិក ប៉ុន្តែការចំណាយប្រចាំថ្ងៃនិងផ្ញើប្រាក់ទៅកាន់គ្រួសារភាគច្រើនជាប្រាក់រៀលប្រមាណជាង ៨០% ដែលបញ្ហានេះនាំឱ្យកម្មករមានការខាតបង់ពេលវេលា និងប្រាក់កាសដោយសារការប្ដូរប្រាក់។ ផ្អែកតាមការអង្កេត កម្មករជាច្រើនក៏បានសម្ដែងការយល់ស្របលើការបើកប្រាក់ឈ្នួលទាំងស្រុង ឬមួយផ្នែកជាប្រាក់រៀលផងដែរ។ ហេតុដូច្នេះ ខ្ញុំសូមយកឱកាសនេះដើម្បីលើកទឹកចិត្តឱ្យក្រុមហ៊ុន-សហគ្រាស គួរបង្កើនការបើកប្រាក់ខែជាប្រាក់រៀល ហើយសូមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ទាំងអស់ ផ្ដល់ជម្រើសឱ្យអតិថិជនទាំងអស់មានលទ្ធភាពក្នុងការប្រើប្រាស់ យូអរកូដ (QR code) ជាប្រាក់រៀល ដើម្បីសម្រួលដល់ការទូទាត់ជាប្រាក់រៀលជាប្រចាំ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើន នឹងជួយពង្រឹងអធិបតេយ្យជាតិនិងការកសាងសង្គមជាតិឱ្យកាន់តែរីកចម្រើន និងប្រកបដោយនិរន្តរភាព។ ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រោងចក្រ ក្រុមហ៊ុន-សហគ្រាស ម្ចាស់អាជីវកម្ម ប្រជាពលរដ្ឋទូទៅ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ បន្តរួមចំណែកប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការរបស់ខ្លួនឱ្យកាន់តែច្រើនឡើង ដូចជា តាមរយៈការទូទាត់ ការបិទស្លាកតម្លៃទំនិញនិងសេវានានា ការផ្ដល់ឥណទាន និងការសន្សំជាប្រាក់រៀល ព្រមទាំងផ្ដល់លក្ខខណ្ឌអនុគ្រោះឱ្យបានច្រើនចំពោះការប្រើប្រាស់ប្រាក់រៀល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា និងប្អូនៗនិស្សិតទាំងអស់ សូមជួបប្រទះពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមចូលរួមប្រើប្រាស់ប្រាក់រៀលទាំងអស់គ្នា "លុយរៀល លុយជាតិ លុយយើង"។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...៤.១៤...០២៤...០០៤...[illegible]

ថ្ងៃ អង្គារ ៣រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០២៤

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី

នៅថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) ស្តីពី "កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់"។

លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង ឯកឧត្តម Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់នេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម Anwar Ibrahim** នាយករដ្ឋមន្ត្រី នៃប្រទេសម៉ាឡេស៊ី និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចនៅប្រទេសម៉ាឡេស៊ី។

អនុស្សរណៈយោគយល់រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ីនេះ ត្រូវបានរៀបចំឡើងជាមូលដ្ឋានសម្រាប់ជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធ ព្រមទាំងលើកកម្ពស់នវានុវត្តន៍ហិរញ្ញវត្ថុ និងការទូទាត់ឆ្លងដែនប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពបន្ថែមទៀត ដើម្បីផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងធុរជនរបស់ប្រទេសទាំងពីរ។ កិច្ចសហប្រតិបត្តិការនេះ មានវិសាលភាពគ្របដណ្តប់លើទម្រង់ជាច្រើនក្នុងការតភ្ជាប់ប្រព័ន្ធទូទាត់នៃប្រទេសទាំងពីរ រាប់បញ្ចូលទាំងការតភ្ជាប់ការទូទាត់ក្នុងស្រុករវាងប្រទេសទាំងពីរ ដើម្បីបើកលទ្ធភាពដល់ការទូទាត់ឆ្លងដែនតាមឃ្យូអរកូត។ ការណ៍នេះ នឹងផ្តល់នូវភាពងាយស្រួលដល់ប្រជាពលរដ្ឋម៉ាឡេស៊ីអាចធ្វើការទូទាត់ដោយស្កេនឃ្យូអរកូតនៅក្នុងប្រទេសកម្ពុជា ហើយប្រជាពលរដ្ឋកម្ពុជាក៏អាចធ្វើការទូទាត់ដោយស្កេនឃ្យូអរកូតនៅក្នុងប្រទេសម៉ាឡេស៊ីទៅវិញទៅមកផងដែរ ដោយប្រើប្រាស់រូបិយវត្ថុក្នុងស្រុកសម្រាប់ការទូទាត់ ព្រមទាំងបានជួយគាំទ្រដល់យន្តការកិច្ចសហការត្រួតពិនិត្យការទូទាត់ឆ្លងដែន ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពនិងសុវត្ថិភាព។

អនុស្សរណៈយោគយល់នេះ នឹងជួយសម្រួលដល់សកម្មភាពពាណិជ្ជកម្ម និងវិស័យទេសចរណ៍របស់ប្រទេសទាំងពីរ ព្រមទាំងជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចក្នុងតំបន់។ ពាណិជ្ជករទូទាត់រាយនៃ

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ប្រទេសទាំងពីរដែលទទួលយកការទូទាត់តាមឃ្យូអរកូដ ប្រមាណ ៥ លានទីតាំង រាប់បញ្ចូលទាំងអាជីវកម្មខ្នាតតូចផងដែរ នឹងទទួលបាននូវអត្ថប្រយោជន៍ពីកិច្ចសហប្រតិបត្តិការនេះ។ អនុស្សរណៈយោគយល់នេះជាជំហានថ្មីមួយក្នុងគំនិតផ្តួចផ្តើមតភ្ជាប់ប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន ដែលស្របទៅនឹងទិសដៅជាយុទ្ធសាស្រ្តរបស់ប្រទេស G20 ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែន។

ឯកឧត្តម Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី បានមានប្រសាសន៍ថា "អនុស្សរណៈយោគយល់នេះ បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់ធនាគារកណ្តាលទាំងពីរក្នុងការលើកកម្ពស់ប្រតិបត្តិការទូទាត់ឆ្លងដែន ការផ្ទេរប្រាក់ និងការទូទាត់ដោយប្រើប្រាស់រូបិយវត្ថុជាតិ។ កិច្ចសហការនេះ នឹងធ្វើឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវកិច្ចសហប្រតិបត្តិការយូរអង្វែងរវាងធនាគារកណ្តាលម៉ាឡេស៊ី និងធនាគារជាតិនៃកម្ពុជា ក្នុងបុព្វហេតុផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងធុរជននៃប្រទេសទាំងពីរ។ ការណ៍នេះ នឹងជាកម្លាំងចលករមួយក្នុងការជំរុញនវានុវត្តន៍ និងសមាហរណកម្មហិរញ្ញវត្ថុ ដែលនឹងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់"។

លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា "ពិធីដ៏សំខាន់នាថ្ងៃនេះ គឺជាការបោះជំហានដ៏សំខាន់មួយ ដើម្បីឆ្ពោះទៅរកការពង្រឹងកិច្ចសហប្រតិបត្តិការរបស់ធនាគារកណ្តាលទាំងពីរ។ តាមរយៈអនុស្សរណៈយោគយល់នេះ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី នឹងសហការគ្នាដើម្បីជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ និងកែលម្អប្រព័ន្ធទូទាត់ឆ្លងដែន សំដៅជំរុញសកម្មភាពពាណិជ្ជកម្ម និងបរិយាបន្នហិរញ្ញវត្ថុរបស់ប្រទេសទាំងពីរ ព្រមទាំងជួយលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ស្របតាមគោលដៅរបស់អាស៊ាន"។

**ទំនាក់ទំនង ៖**

អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦

អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia ,

www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia ,

www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

ប្រអប់សំបុត្រលេខ ២៥, អគារលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា និងឯកឧត្តម Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់



នាថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង **ឯកឧត្តម** Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ នៅប្រទេសម៉ាឡេស៊ី។

ពិធីចុះហត្ថលេខានេះរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម** Anwar Ibrahim **នាយករដ្ឋមន្ត្រី** នៃប្រទេសម៉ាឡេស៊ី នៅក្នុងកិច្ចប្រជុំទ្វេភាគី អំឡុងដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចធិបតី នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ពីថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០២៤។ អនុស្សរណៈយោគយល់នេះត្រូវបានរៀបចំឡើង ដើម្បីជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធ ព្រមទាំងលើកកម្ពស់នវានុវត្តន៍ហិរញ្ញវត្ថុ និងការទូទាត់ឆ្លងដែនប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពបន្ថែមទៀត សំដៅផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងធុរជនរបស់ប្រទេសទាំងពីរ ព្រមទាំងជួយលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកសម្រាប់ការទូទាត់ និងគាំទ្រដល់យន្តការកិច្ចសហការត្រួតពិនិត្យការទូទាត់ឆ្លងដែនឱ្យកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាពផងដែរ



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី




នៅថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង **ឯកឧត្តម** Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។ កិច្ចប្រជុំនេះមានគោលបំណងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអភិវឌ្ឍវិស័យធនាគារក្នុងប្រទេសទាំងពីរ និងត្រួតពិនិត្យវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយគ្នានាពេលកន្លងមក ក៏ដូចជារឹតចំណងមិត្តភាពរវាងធនាគារកណ្តាលទាំងពីរឱ្យកាន់តែរឹងមាំ។ ថ្នាក់ដឹកនាំទាំងពីរបានពិភាក្សាផ្លាស់ប្តូរយោបល់អំពីស្ថានភាពសេដ្ឋកិច្ច ដំណើរការអភិវឌ្ឍន៍វិស័យធនាគារ នយោបាយរូបិយវត្ថុ និងការងារធនាគារកណ្តាល ហើយបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពនៃកិច្ចសហ-



ប្រតិបត្តិការនាពេលកន្លង ដែលបានរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចនៃប្រទេសទាំងពីរយ៉ាងល្អប្រសើរ។ ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការទ្វេភាគី តាមរយៈការចុះអនុស្សរណៈយោគយល់ជាលើកដំបូងក្នុងឆ្នាំ២០១០ សំដៅលើកកម្ពស់នវានុវត្តន៍ហិរញ្ញវត្ថុ ការអភិវឌ្ឍប្រព័ន្ធទូទាត់ ការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែន និងយន្តការត្រួតពិនិត្យប្រព័ន្ធធនាគារជាដើម។ កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍធនធានមនុស្សក៏ត្រូវបានបង្កើនជាបន្តបន្ទាប់ តាមរយៈទស្សនកិច្ចសិក្សា និងសិក្ខាសាលាចែករំលែកចំណេះដឹង។ ឆ្លៀតក្នុងឱកាសនោះដែរ លោកជំទាវទេសាភិបាល ក៏បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំធនាគារឯកជនម៉ាឡេស៊ី រួមមាន ធនាគារ Public Bank Group និងធនាគារ Maybank Group ដែលមានបុត្រសម្ព័ន្ធនៅប្រទេសកម្ពុជាផងដែរ ទាក់ទងនឹងការវិនិយោគពាណិជ្ជកម្ម និងវិស័យហិរញ្ញវត្ថុ ក៏ដូចជា កិច្ចសម្របសម្រួលសម្រាប់ប្រតិបត្តិការទូទាត់។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលអំពីបរិយាបន្នហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០២៤ នៃវេទិកាសេដ្ឋកិច្ចពិភពលោក

កាលពីថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលអំពីបរិយាបន្នហិរញ្ញវត្ថុនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០២៤ នៃវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) នៅទីក្រុងដាវូស (Davos) ប្រទេសស្វីស ដែលបានប្រព្រឹត្តិទៅពីថ្ងៃទី១៥ - ១៩ ខែមករា ឆ្នាំ២០២៤។ នេះជាសកម្មភាពចូលរួមចំណែកយ៉ាងសំខាន់របស់ លោកជំទាវ ទេសាភិបាល ក្នុងការលើកកម្ពស់កិត្យានុភាពជាតិលើឆាកអន្តរជាតិ តាមរយៈការចែករំលែកបទពិសោធន៍ ក៏ដូចជា ទស្សនៈជុំវិញប្រធានបទដ៏សំខាន់ៗជាមួយថ្នាក់ដឹកនាំកំពូល




ទាំងក្នុងវិស័យសាធារណៈ និងឯកជន ដូចជាវត្តមានចូលរួមដ៏ខ្ពង់ខ្ពស់របស់ **ព្រះមហាក្សត្រីនៃប្រទេសហុល្លង់** (H.M. Queen Máxima of the Netherlands) និងឥស្សរជនលំដាប់អន្តរជាតិជាច្រើនរូបទៀត។






# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាសន្និសីទថ្នាក់ទេសាភិបាលនៃស៊ាសិន




នៅថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងកិច្ចពិភាក្សាក្រោមប្រធានបទ "គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល៖ តួនាទីនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលក្នុងបរិយាបន្នហិរញ្ញវត្ថុ" នៅក្នុងសន្និសីទថ្នាក់ទេសាភិបាលនៃមជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្តុះបណ្តាលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន) លើកទី៥៩ នៅទីក្រុងមុំបៃ ប្រទេសឥណ្ឌា។ សន្និសីទនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ជាវេទិកាសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុ ដែលជាសមាជិកស៊ាសិន ព្រមទាំងមានការចូលរួមពីតំណាងជាន់ខ្ពស់មកពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដើម្បីពិភាក្សាលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុក្នុងតំបន់។ លោកជំទាវទេសាភិបាលបានជម្រាបជូនអង្គសន្និសីទពីសារៈសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលដែលបានក្លាយជាការងារអាទិភាពក្នុងផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជា។ លោកជំទាវបណ្ឌិតក៏បានចែករំលែកបទពិសោធន៍ទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ជាពិសេសប្រព័ន្ធទូទាត់បាគង ដែលជាប្រព័ន្ធទូទាត់កន្លោងជំនាន់ថ្មីរបស់ប្រទេសកម្ពុជា ដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឌីជីថលូបនីយកម្ម ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងបានតភ្ជាប់ការទូទាត់ជាមួយប្រព័ន្ធទូទាត់របស់បណ្តាប្រទេសជាច្រើនដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់ឆ្លងដែន។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាពិភាក្សា ស្តីពី "ការបង្កើតអនាគតបច្ចេកវិទ្យាហិរញ្ញវត្ថុ៖ កិច្ចពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ញាសិប្បនិម្មិត (AI)"



នាថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាពិភាក្សាស្តីពី "ការបង្កើតអនាគតបច្ចេកវិទ្យាហិរញ្ញវត្ថុ៖ កិច្ចពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ញាសិប្បនិម្មិត (AI)" នៅប្រទេសជប៉ុន ក្នុងកម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុន ឆ្នាំ២០២៤ កម្មវិធីនេះមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់បណ្តាធនាគារកណ្តាល អ្នកជំនាញផ្នែកហិរញ្ញវត្ថុលំដាប់ពិភពលោក ព្រមទាំងតំណាងជាន់ខ្ពស់មកពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដើម្បីពិភាក្សាលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍ សំដៅចែករំលែកពីទស្សនៈរបស់អ្នកជំនាញ និងអ្នកតាក់តែងគោលនយោបាយ។ ការចូលរួមរបស់លោកជំទាវទេសាភិបាល ក្នុងនាមជាវាគ្មិនកិត្តិយសក្នុងវេទិកាលំដាប់ពិភពលោកនេះ ឆ្លុះបញ្ចាំងពីការរីក-ចម្រើននៃប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា និងទស្សនអនាគតច្បាស់លាស់របស់លោកជំទាវក្នុងការដឹកនាំធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យបានឆ្លើយតបនឹងនិន្នាការហិរញ្ញវត្ថុសកល ក៏ដូចជាផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាទូទៅ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលនៃស៊ាសិន លើកទី៤៣



នៅថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលនៃមជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្តុះបណ្តាលធនាគារកណ្តាលអាស៊ី-អាគ្នេយ៍ (ស៊ាសិន) លើកទី៤៣ នៅទីក្រុងមុំបៃ ប្រទេសឥណ្ឌា។ អង្គប្រជុំបានពិនិត្យមើលលទ្ធផលដែលមជ្ឈមណ្ឌលស៊ាសិនសម្រេចបាននៅក្នុងឆ្នាំ២០២៣ និងបានដាក់ចេញនូវផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៤ ក្នុងនោះរួមមានការអនុម័តលើគម្រោងថវិកា ការអនុវត្តកម្មវិធីបណ្តុះបណ្តាលនិងស្រាវជ្រាវ និងការងាររអាទិភាពផ្សេងៗមួយចំនួនទៀត។ នាឆ្នាំ២០២៣កន្លងទៅ ធនាគារជាតិនៃកម្ពុជា បានធ្វើជាប្រធានប្តូរវេននៃមជ្ឈមណ្ឌលស៊ាសិន និងបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំពាក់ព័ន្ធប្រកបដោយជោគជ័យ លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ ព្រមទាំងបានពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងសមាជិក។ បណ្តាធនាគារកណ្តាល និងអាជ្ញាធររូបិយវត្ថុជាសមាជិកមជ្ឈមណ្ឌលស៊ាសិនបានវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណចំពោះការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់ការបំពេញតួនាទីជាប្រធានប្រកបដោយប្រសិទ្ធភាព។ នាឆ្នាំ២០២៤នេះ ធនាគារកណ្តាលឥណ្ឌាធ្វើជាប្រធានប្តូរវេន មជ្ឈមណ្ឌលស៊ាសិន ហើយនៅឆ្នាំ២០២៥ ធនាគារកណ្តាលកូរ៉េនឹងបន្តធ្វើជាប្រធាន។ គួរបញ្ជាក់ថា មជ្ឈមណ្ឌលស៊ាសិនមានសមាជិកជាធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុចំនួន ១៩ ដែលរួមមាន ព្រុយណេ កម្ពុជា ចិន ហុងកុង ឥណ្ឌា ឥណ្ឌូណេស៊ី កូរ៉េខាងត្បូង ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី មីយ៉ាន់ម៉ា នេប៉ាល់ ហ្វីលីពីន សិង្ហបុរី ស្រីលង្កា ប៉ាពួអាស៊ីនូវែលហ្គីណេ ចិនតៃប៉ិ ថៃ និងវៀតណាម។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន គ.ស.ហ. នៅរាជធានីភ្នំពេញ*

នាថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន គ.ស.ហ. នៅរាជធានីភ្នំពេញ។ កិច្ចប្រជុំនេះក៏មានវត្តមានចូលរួមពីសមាជិកចំនួន ១១៨ រូប មកពី ២៨ ក្រសួង-ស្ថាប័ន ដើម្បីពិនិត្យ និងពិភាក្សាលើ ១/-វឌ្ឍនភាពការងារវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ២/-វឌ្ឍនភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីក-សាយភាយអាវុធមហាប្រល័យ ក្រោយចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force-FATF) និង៣/-ទិសដៅការងារបន្ត។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវបណ្ឌិត អាមីដា សាល់សៃ អាលីហ្សាបាណា



*លោកជំទាវបណ្ឌិត អាមីដា សាល់សៃ អាលីហ្សាបាណា អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ និងជា លេខាធិការប្រតិបត្តិអង្គការ UN-ESCAP*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

កាលពីថ្ងៃចន្ទ ១២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សា ការងារជាមួយ **លោកជំទាវបណ្ឌិត អាមីដា សាល់សៃ អាលីហ្សាបាណា** (Ms. Armida Salsiah Alisjahbana) អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ និងជាលេខាធិការប្រតិបត្តិអង្គការ UN-ESCAP ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់លោកជំទាវនៅកម្ពុជា និងបានទស្សនាសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុព្រះស្រីល្បសានវរ្ម័ន (ស.ស.រ)។ លោជំទាវ អាមីដា សាល់សៃ អាលីហ្សាបាណា បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាង UN-ESCAP និងធនាគារជាតិនៃកម្ពុជា ដោយបានផ្តល់ផលវិជ្ជមានក្នុងការលើកកម្ពស់








សហគ្រិនស្ត្រី និងការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ បរិស្ថាន និងសង្គម ព្រមទាំងបានកោតសរសើរពីការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធធនាគារកម្ពុជា និងការធ្វើឌីជីថលូបនីកម្មនៃប្រព័ន្ធទូទាត់ផងដែរ។ ជាមួយគ្នានេះ លោកជំទាវទេសាភិបាល បានថ្លែងអំណរគុណចំពោះ លោកជំទាវអគ្គលេខាធិការរង ដែលបានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញមកជួបសម្តែងការគួរសមនិងពិភាក្សាការងារ។ លោកជំទាវបានថ្លែងអំណរគុណដល់ UN-ESCAP ជាពិសេស លោកជំទាវអគ្គលេខាធិការរងផ្ទាល់ ដែលគាំទ្រដល់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ស្ត្រី និងសហគ្រិនភាពស្ត្រី និងបានជួយរៀបចំផែនការចង្អុលទិសហិរញ្ញប្បទានប្រកបដោយចីរភាពនៅកម្ពុជា ស្របតាមទិសដៅអាទិភាពរបស់ធនាគារជាតិនៃកម្ពុជាលើការរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ដោយផ្តោតលើបញ្ហាការប្រែប្រួលអាកាសធាតុ បរិស្ថាននិងសង្គម។

លោកជំទាវបណ្ឌិតក៏បានជម្រាបជូនពីគោលដៅនៃការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ តាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ ដើម្បីសម្រួលដល់ការទូទាត់ភាពងាយទទួលបានសេវាទូទាត់ និងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។ លោជំទាវ អាមីដា បានកោតសរសើរចំពោះការរៀបចំរបស់សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ដែលពិតជាបានផ្តល់នូវចំណេះដឹងទាំងផ្នែកប្រវត្តិសាស្ត្រ សេដ្ឋកិច្ច និងរូបិយវត្ថុ ក្នុងរយៈពេល ២ សតវត្សរ៍ប្រកបដោយភាពរស់រវើក និងទាន់សម័យ។ លោកជំទាវ អាមីដា ក៏បានបង្ហាញឆន្ទៈបន្តគាំទ្ររបស់ UN-ESCAP លើការងារដែលបាននិងកំពុងអនុវត្តរួមគ្នាផ្អែកលើស្មារតីនៃអនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីការលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាពនៅកម្ពុជា សំដៅគាំទ្ររាជរដ្ឋាភិបាលក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបានធ្វើឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយលោកស្រី Eteri Kvintradze



*លោកស្រី Eteri Kvintradze ប្រធានការិយាល័យអភិវឌ្ឍន៍សមត្ថភាពនៃមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយ **លោកស្រី** Eteri Kvintradze ប្រធានការិយាល័យអភិវឌ្ឍន៍សមត្ថភាពនៃមូលនិធិ-រូបិយវត្ថុអន្តរជាតិប្រចាំប្រទេសថៃ (CDOT) និង **លោកបណ្ឌិត** Jochen M. Schmittmann តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងតំបន់សម្រាប់កម្ពុជា ឡាវ និងវៀតណាម នៅធនាគារជាតិនៃកម្ពុជា។ ក្នុងជំនួបនេះ លោកស្រី Eteri Kvintradze បានវាយតម្លៃខ្ពស់ចំពោះប្រសិទ្ធភាពអនុវត្តជំនួយបច្ចេកទេសដែលធនាគារជាតិនៃកម្ពុជា ទទួលបានពីការិយាល័យ CDOT ក៏ដូចជា IMF នាពេលកន្លងមក ជាពិសេសសម្រាប់ការងារតាមដាននិងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ព្យាករណ៍សន្ទនីយភាព





និងស្រង់ទិន្នន័យស្ថិតិ។ ក្នុងឱកាសនេះដែរ លោកស្រី Eteri Kvintradze ក៏បានណែនាំ **លោក** Renato Perez ទីប្រឹក្សាថ្មីផ្នែកស្ថិតិវិស័យខាងក្រៅប្រចាំការិយាល័យ CDOT ដែលនឹងបំពេញបេសកកម្មពង្រឹងគុណភាពស្ថិតិនៅធនាគារជាតិនៃកម្ពុជា។ លោកស្រីក៏បានកោតសរសើរសមត្ថភាពមន្ត្រី-បុគ្គលិក និងស្មារតីប្តេជ្ញារបស់ធនាគារជាតិនៃកម្ពុជាក្នុងការបោះផ្សាយទិន្នន័យស្ថិតិ ដូចជា ស្ថិតិជញ្ជីងទូទាត់ ស្ថានភាពវិនិយោគអន្តរជាតិ (IIP) ជាដើម។ លោកស្រីបានស្នើសុំកិច្ចសហការពីធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំកិច្ចប្រជុំថ្នាក់តំបន់ប្រចាំឆ្នាំរបស់គណៈកម្មាធិការប្រឹក្សាយោបល់ជំនួយបច្ចេកទេសរបស់ការិយាល័យ CDOT ដើម្បីពិភាក្សាអំពីប្រសិទ្ធភាពជំនួយបច្ចេកទេស និងកំណត់ទិសដៅជំនួយបច្ចេកទេសសម្រាប់ប្រទេសកម្ពុជា វៀតណាម និងឡាវ។ ជាការឆ្លើយតប លោកជំទាវទេសាភិបាល បានថ្លែងអំណរគុណចំពោះការិយាល័យ CDOT ក៏ដូចជា IMF ដែលតែងតែផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា។ តាមរយៈជំនួយបច្ចេកទេសទាំងនោះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងលើកកម្ពស់គោលនយោបាយនិងវិធានការ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តនយោបាយរូបិយវត្ថុ និងអភិវឌ្ឍនវិស័យធនាគារ។ លោកជំទាវបណ្ឌិតក៏បានឯកភាពផ្តល់កិច្ចសហការរៀបចំកិច្ចប្រជុំថ្នាក់តំបន់ប្រចាំឆ្នាំរបស់គណៈកម្មការប្រឹក្សាយោបល់ជំនួយបច្ចេកទេសរបស់ការិយាល័យ CDOT ក្នុងពេលខាងមុខឆាប់ៗនេះផងដែរ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា



*ឯកឧត្តម Justin Whyatt ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំកម្ពុជា*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃពុធ ១៤កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូស្ថានទូតអូស្ត្រាលី ប្រចាំនៅកម្ពុជា ដឹកនាំដោយ **ឯកឧត្តម** Justin Whyatt ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំកម្ពុជា នៅធនាគារជាតិនៃកម្ពុជា។ ក្នុងជំនួបនេះ ថ្នាក់ដឹកនាំស្ថាប័នទាំងពីរ បានពិភាក្សាពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ឥទ្ធិពលនៃការថមថយកំណើនសេដ្ឋកិច្ចពិភពលោក និងការអភិវឌ្ឍប្រព័ន្ធធនាគារនិងទូទាត់នៅកម្ពុជា។ លោកជំទាវទេសាភិបាល បានជម្រាបជូនពីស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៣ និងព្យាករណ៍ឆ្នាំ២០២៤ ថាបន្តងើបឡើងជាលំដាប់ ជាមួយកម្រិតទាបនៃអតិផរណា បើទោះជាមានបញ្ហាប្រឈមមួយចំនួនក៏ដោយ។ ប្រព័ន្ធធនាគារបន្តមានភាពរឹងមាំ និងបានរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ច ស្របពេលដែលការកើនឡើងនៃអត្រាឥណទានមិនដំណើរការស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន និងរំពឹងថានឹងថយចុះមកវិញក្នុងពេលខាងមុខ។ នាឱកាសនោះ ឯកឧត្តមឯកអគ្គរាជទូត ក៏បានអបអរសាទរ ចំពោះវឌ្ឍនភាពនៃការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជា ដែលបានតភ្ជាប់ជាមួយប្រព័ន្ធទូទាត់របស់បណ្តាប្រទេសក្នុងតំបន់។ ជារួម លោកជំទាវបណ្ឌិត និងឯកឧត្តមឯកអគ្គរាជទូត បានបង្ហាញឆន្ទៈពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នាឱ្យកាន់តែរឹងមាំថែមទៀត ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ជាពិសេសកិច្ចសហប្រតិបត្តិការលើផ្នែកហិរញ្ញប្បទានបៃតង និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយនាយកប្រតិបត្តិនៃអង្គការ Conservation International



*លោកបណ្ឌិត M. Sanjayan នាយកប្រតិបត្តិ នៃអង្គការ Conservation International*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ **លោកបណ្ឌិត M. Sanjayan** នាយកប្រតិបត្តិនៃអង្គការ Conservation International អំពីនវានុវត្តន៍ផ្នែកហិរញ្ញវត្ថុសម្រាប់ការអភិរក្សធនធានធម្មជាតិ ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការជួញដូរឥណទានកាបូនសម្រាប់ប្រទេសកម្ពុជា។ លោកជំទាវ ទេសាភិបាល បានលើកឡើងអំពីសក្តានុពលសម្រាប់កម្ពុជា ក្នុងការទាញយកប្រាក់ចំណូលពីការជួញដូរឥណទានកាបូននៅទីផ្សារអន្តរជាតិ ដោយសារបច្ចុប្បន្នកម្ពុជាមានការបញ្ចេញឧស្ម័នកាបូនទាប និងមានគម្របព្រៃឈើខ្ពស់ ដែលអំណោយផលដល់ការបង្កើតឥណទានកាបូន។ ក្នុងនាមជាទេសាភិបាលធនាគារកណ្តាល លោកជំទាវបណ្ឌិតបានបង្ហាញពីឆន្ទៈខ្ពស់ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ទីផ្សារឥណទានកាបូនសម្រាប់ប្រទេសកម្ពុជាលើទីផ្សារអន្តរជាតិ។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូជួបប្រជុំពិភាក្សាការងារជាមួយស្ថាប័ន NPCI International Payments Limited



នៅថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូជួបប្រជុំពិភាក្សាការងារជាមួយស្ថាប័ន NPCI International Payments Limited (NIPL) នៅទីក្រុងមុំបៃ ប្រទេសឥណ្ឌា។ ជំនួបពិភាក្សានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពន្លឿនសកម្មភាពអនុវត្តគម្រោងទូទាត់ឆ្លងដែន រវាងប្រទេសកម្ពុជា និងប្រទេសឥណ្ឌា ឱ្យមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងឆ្លុះបញ្ចាំងពីភាពរួចរាល់របស់ភាគីទាំងសងខាង។ គួររំឭកថា កាលពីថ្ងៃ១៧ ខែមីនា ឆ្នាំ២០២៣ កន្លងទៅ ធនាគារជាតិនៃកម្ពុជា និងស្ថាបន័ NIPL បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ច-សហប្រតិបត្តិការលើការទូទាត់ និងការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសឥណ្ឌា។ កិច្ចសហការនេះនឹងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសម្រួលដល់ប្រតិបត្តិការទូទាត់ឆ្លងដែនឱ្យកាន់តែងាយស្រួល សុវត្ថិភាព និងប្រសិទ្ធភាព ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ទេសចរណ៍ និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ឱ្យកាន់តែមានសក្តានុពលថែមទៀត។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយក្រុមប្រឹក្សាធុរកិច្ច អាមេរិក-អាស៊ាន



*លោក Brian D. McFeeters អនុប្រធានជាន់ខ្ពស់ និងជា នាយកគ្រប់គ្រងក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាធុរកិច្ច អាមេរិក-អាស៊ាន ដឹកនាំដោយ **លោក** Brian D. McFeeters អនុប្រធានជាន់ខ្ពស់ និងជានាយកគ្រប់គ្រងក្រុមប្រឹក្សាធុរកិច្ច អាមេរិក-អាស៊ាន ក្នុងគោលបំណងផ្លាស់ប្តូរយោបល់ពីការប្រកបអាជីវកម្មនិងសក្តានុពលវិនិយោគរបស់ក្រុមហ៊ុនធំៗរបស់សហរដ្ឋអាមេរិក។ ថ្នាក់ដឹកនាំក្រុមហ៊ុនដែលបានចូលរួមក្នុងជំនួបនោះរួមមានដូចជាថ្នាក់ដឹកនាំមកពីក្រុមហ៊ុន VISA Mastercard Ford និងក្រុមហ៊ុនអាមេរិកជាច្រើនទៀត។ កិច្ចប្រជុំបានពិភាក្សាអំពីវឌ្ឍនភាពអាជីវកម្ម បញ្ហាប្រឈម និងទស្សនវិស័យរបស់ធនាគារជាតិនៃកម្ពុជា លើការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នាឱកាសនោះ លោកជំទាវទេសាភិបាល បានជម្រាបជូនពីទស្សនវិស័យវិជ្ជមាននៃសេដ្ឋកិច្ចកម្ពុជា ការរីកចម្រើន និងបញ្ហាប្រឈមក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំងសក្តានុពលសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា។ លោកជំទាវក៏បានជម្រាបជូនពីគោលនយោបាយទាក់ទាញវិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ចផងដែរ។ កិច្ចពិភាក្សាបានលើកឡើងពីការរីកចម្រើនប្រព័ន្ធធនាគារនិងទូទាត់ ដែលក្នុងនោះការទូទាត់តាមអេឡិចត្រូនិកបានកើនឡើងយ៉ាងឆាប់រហ័ស ហើយសូមថ្លែងអំណរគុណក្រុមហ៊ុនអាមេរិកពាក់ព័ន្ធដែលបានរួមចំណែកក្នុងការធ្វើឌីជីថលូបនីយកម្មប្រព័ន្ធទូទាត់ និងក្នុងដំណើរការអភិវឌ្ឍវិស័យធនាគារ។ លោកជំទាវក៏បានជម្រាបជូនផងដែរថា ធនាគារជាតិនៃកម្ពុជា បានរួមចំណែកលើកកម្ពស់តម្លាភាពបរិយាបន្នហិរញ្ញវត្ថុ និងបានតភ្ជាប់ការទូទាត់នៅក្នុងតំបន់។ លោកជំទាវទេសាភិបាលបានលើកទឹកចិត្តឱ្យក្រុមហ៊ុនសហរដ្ឋអាមេរិកមកវិនិយោគនៅកម្ពុជាឱ្យកាន់តែច្រើន ក្នុងស្ថានភាពដែលកម្ពុជាមានសក្តានុពលជាច្រើនរួមមានវិស័យកម្មន្តសាល ទេសចរណ៍ កសិកម្ម និងហិរញ្ញវត្ថុ ជាដើម ជាមួយសុទិដ្ឋិនិយមខ្ពស់ចំពោះកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគត។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិចូលជួបសម្តែងការគួរសម និង ពិភាក្សាការងារ



នាថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយ **លោក** Davide Furceri ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ លោក Davide Furceri បានជម្រាបជូនពីគោលបំណងនៃការបំពេញបេសកកម្មប្រចាំឆ្នាំ ដើម្បីជួបពិភាក្សាជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធលើស្ថានភាពសេដ្ឋកិច្ចកម្ពុជា (Staff Visit) ចាប់ពីថ្ងៃទី១២-១៩ ខែមីនា ឆ្នាំ២០២៤។ លោកជំទាវទេសាភិបាល បានស្វាគមន៍ក្រុមបេសកកម្ម និងរង់ចាំពិភាក្សាលើការវិភាគ វាយតម្លៃបឋមរបស់ IMF។ ឆ្លៀតក្នុងឱកាសនេះដែរ លោកជំទាវបានថ្លែងអំណរគុណចំពោះ IMF ដែលបានតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចកម្ពុជា ជាពិសេសការចូលរួមចំណែករបស់ IMF ក្នុងការអភិវឌ្ឍវិស័យធនាគារ ក៏ដូចជាការផ្តល់ជំនួយបច្ចេកទេស អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលសម្រាប់កសាងធនធានមនុស្សនៅកម្ពុជា។ ទន្ទឹមនេះ លោកជំទាវក៏បានស្នើ IMF បន្តវិភាគឱ្យបានស៊ីជម្រៅលើបញ្ហាប្រឈម និងហានិភ័យចម្បងៗចំពោះសេដ្ឋកិច្ចកម្ពុជា និងស្នើឱ្យធ្វើការសិក្សារួមគ្នាលើប្រធានបទសំខាន់ ដែលអាចផ្តល់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយ ក្នុងដំណាក់ដែលសេដ្ឋកិច្ចកំពុងងើបចេញពីវិបត្តិ។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម Nkubito Manzi BAKURAMUTSA ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល*
*ធនាគារជាតិនៃកម្ពុជា*



*ឯកឧត្តម Nkubito Manzi BAKURAMUTSA*
*ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា*

នៅថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ **ឯកឧត្តម** Nkubito Manzi BAKURAMUTSA ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋរវ៉ាន់ដា (Republic of Rwanda) ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុងសេអ៊ូល នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ។ នាឱកាសនោះ លោកជំទាវទេសាភិបាល បានជម្រាបជូនឯកឧត្តមឯកអគ្គរដ្ឋទូត ពីទស្សនវិស័យវិជ្ជមាននៃសេដ្ឋកិច្ចកម្ពុជា ការរីកចម្រើន និងដំណើរអភិវឌ្ឍន៍នៃវិស័យធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងសក្តានុពលសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា។ លោកជំទាវក៏បានជម្រាបជូនឯកឧត្តម ពីគោលនយោបាយទាក់ទាញវិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ចផងដែរ។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅរបស់លោកជំទាវបណ្ឌិតទេសាភិបាល និងត្រៀមខ្លួនរួចជាស្រេចក្នុងការរួមចំណែកពង្រឹងកិច្ចសហការរវាងប្រទេសទាំងពីរ ជាពិសេសលើប្រព័ន្ធទូទាត់។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)



នៅថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមសំណេះ-សំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១៣ នៃទិវាអន្តរជាតិនារី នៅវិទ្យាស្ថាន CDRI ដោយមានមន្ត្រី-បុគ្គលិកចូលរួមសរុបប្រមាណ ៧០រូប។ **ឯកឧត្តមបណ្ឌិត ម៉ី កល្យាណ** ទីប្រឹក្សាជាន់ខ្ពស់ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាប្រធានក្រុម-ប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ លោកជំទាវទេសាភិបាល និងបានជម្រាបជូនពីវឌ្ឍនភាព និងសមិទ្ធផលនៃសកម្មភាពស្រាវជ្រាវ របស់វិទ្យាស្ថាន CDRI ដែលគ្របដណ្តប់លើវិស័យជាច្រើនដូចជា កសិកម្ម អប់រំ បរិស្ថាន សេដ្ឋកិច្ច និងអភិបាលកិច្ច ជាដើម។ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះ **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា ដែលបានរួមចំណែកក្នុងការអភិវឌ្ឍវិទ្យាស្ថាន CDRI ចាប់តាំងពីពេលដែលវិទ្យាស្ថាននេះត្រូវបានបង្កើតឡើង នាដើមទសវត្សរ៍ឆ្នាំ១៩៩០ រហូតមក។ លោកជំទាវ បានវាយតម្លៃខ្ពស់ចំពោះសកម្មភាពចូលរួមចំណែករបស់វិទ្យាស្ថាន CDRI ក្នុងវិស័យស្រាវជ្រាវនៅប្រទេសកម្ពុជា។ លោកជំទាវក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការស្រាវជ្រាវ និងលើកទឹកចិត្តឱ្យបន្តលើកកម្ពស់វប្បធម៌ស្រាវជ្រាវបន្ថែមទៀត ដើម្បីផ្តល់ជាធាតុចូលដល់ការដាក់ចេញគោលនយោបាយ និងគាំទ្រដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយចីរភាព។






## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

### ធនាគារជាតិនៃកម្ពុជា ដឹកនាំប្រតិភូធនាគារជាតិនៃកម្ពុជា គោរពព្រះវិញ្ញាណក្ខន្ធព្រះសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស



នៅថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំប្រតិភូធនាគារជាតិនៃកម្ពុជា គោរពព្រះវិញ្ញាណក្ខន្ធព្រះសព **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស យាងចូលព្រះទិវង្គត នៅវេលាម៉ោង ៥:៤០នាទីល្ងាច ថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ក្នុងព្រះជន្មាយុ ៩៣ព្រះវស្សា ដោយព្រះជរាពាធ។ យើងខ្ញុំព្រះអង្គ ជាថ្នាក់ដឹកនាំ និងមន្ត្រីធនាគាជាតិនៃកម្ពុជា សូមក្រាបឧទ្ទិសថ្វាយព្រះមហាកុសល ដល់ព្រះវិញ្ញាណក្ខន្ធ សម្តេចព្រះមហាសង្ឃរាជាធិបតិកិត្តិឧទ្ទេសបណ្ឌិត សូមយាងទៅកាន់ព្រះសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូអញ្ជើញគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង អតីតសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា



នាថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំប្រតិភូអញ្ជើញគោរពវិញ្ញាណក្ខន្ធ **ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង** អតីតសមាជិកក្រុមប្រឹក្សាភិបាល ធនាគារជាតិនៃកម្ពុជា តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា ដែលបានទទួលមរណភាពនៅថ្ងៃសុក្រ ទី៨ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១១:១៥នាទីយប់ ក្នុងជន្មាយុ ៧៦ឆ្នាំ ដោយរោគាពាធ។ ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រី-បុគ្គលិកទាំងអស់នៃធនាគារជាតិនៃកម្ពុជា សូមបួងសួងឱ្យដួងវិញ្ញាណក្ខន្ធរបស់ ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញពិនិត្យការប្រឡងជ្រើសរើសបុគ្គលិកចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា ក្នុងក្របខ័ណ្ឌលេខាធិការ "គ"

នាថ្ងៃអាទិត្យ ២កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញពិនិត្យការប្រឡងជ្រើសរើសបុគ្គលិកចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជាក្នុងក្របខ័ណ្ឌលេខាធិការ "គ" កម្រិតសញ្ញាបត្រប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ដែលត្រូវបានរៀបចំឡើងនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ។ បេក្ខជន-បេក្ខនារីប្រមាណ ៣៧០ រូប បានចូលរួមក្នុងការប្រឡងនេះ។ ការជ្រើសរើសបុគ្គលិកបន្ថែមនេះធ្វើឡើងដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការធនធានមនុស្ស សម្រាប់បំពេញមុខងារភារកិច្ចកាន់តែច្រើនឡើងនៅ ធនាគារជាតិនៃកម្ពុជា។





# អត្រាប្តូរប្រាក់ប្រចាំខែ

## (អត្រាប្តូរចុងខែ)

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | គម្លាតអត្រាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|
| | ទិញ | លក់ | មធ្យម | ប្រែប្រួលប្រចាំខែ | | មធ្យម | ប្រែប្រួលប្រចាំខែ | | អត្រាផ្លូវការ-ទីផ្សារ | |
| | | | | +/- | % | | +/- | % | +/- | % |
| **២០២១** | | | | | | | | | | |
| មេសា | ៤.០៦៨ | ៤.០៨៣ | ៤.០៧៦ | ៦ | 0,១៥ | ៤.០៤៨ | ៣ | 0,0៧ | ២៨ | 0,៦៨ |
| ឧសភា | ៤.១០៧ | ៤.១១៦ | ៤.១១២ | ៣៩ | 0,៩៦ | ៤.០៧២ | ២៤ | 0,៥៩ | ៣៧ | 0,៩0 |
| មិថុនា | ៤.១០២ | ៤.១១២ | ៤.១០៧ | -៥ | -0,១២ | ៤.០៧៥ | ៣ | 0,0៧ | ២៩ | 0,៧១ |
| កក្កដា | ៤.១០៧ | ៤.១១៧ | ៤.១១២ | ៥ | 0,១២ | ៤.០៧២ | -៣ | -0,0៧ | ៤0 | 0,៩៨ |
| សីហា | ៤.១១៩ | ៤.១២៩ | ៤.១២៤ | ១២ | 0,២៩ | ៤.០៨០ | ៨ | 0,២0 | ៤៤ | ១,0៤ |
| កញ្ញា | ៤.១១៩ | ៤.១៣០ | ៤.១២៥ | 0 | - | ៤.០៧៩ | -១ | -0,0២ | ៤៤ | ១,0៨ |
| តុលា | ៤.០៩៩ | ៤.១០៩ | ៤.១០៤ | -២0 | -0,៤៩ | ៤.០៦៦ | -១៣ | -0,៣២ | ៣៧ | 0,៩0 |
| វិច្ឆិកា | ៤.១០២ | ៤.១១៣ | ៤.១០៨ | ៣ | 0,0៧ | ៤.០៦៩ | ៣ | 0,0៧ | ៣៦ | 0,៨៨ |
| ធ្នូ | ៤.១០៩ | ៤.១១៨ | ៤.១១៤ | ៧ | 0,១៧ | ៤.០៧៤ | ៥ | 0,១២ | ៤0 | 0,៩៧ |
| **២០២២** | | | | | | | | | | |
| មករា | ៤.០៨៨ | ៤.០៩៨ | ៤.០៩៣ | -២១ | -0,៥១ | ៤.០៦៦ | -៨ | -0,២0 | -២៧ | -0,៦៦ |
| កុម្ភៈ | ៤.០៨៦ | ៤.០៩៤ | ៤.០៩១ | -២ | -0,0៥ | ៤.០៦៦ | 0 | 0,00 | -២៥ | -0,៦១ |
| មីនា | ៤.០៦៨ | ៤.០៧៨ | ៤.០៧៣ | -១៨ | -0,៤៤ | ៤.០៥០ | -១៦ | -0,៣៩ | -២៣ | -0,៥៧ |
| មេសា | ៤.០៦៨ | ៤.០៨០ | ៤.០៧៤ | 0 | 0,00 | ៤.០៤៦ | -៤ | -0,១0 | -២៨ | -0,៦៩ |
| ឧសភា | ៤.០៨៨ | ៤.០៩៧ | ៤.០៩៣ | ២0 | 0,៤៩ | ៤.០៦២ | ១៦ | 0,៤0 | ៣១ | 0,៧៥ |
| មិថុនា | ៤.០៩១ | ៤.១០០ | ៤.០៩៦ | ៣ | 0,0៧ | ៤.០៧០ | ៨ | 0,២0 | ២២ | 0,៥៤ |
| កក្កដា | ៤.០៩៧ | ៤.១០៤ | ៤.១០១ | ៦ | 0,១៥ | ៤.០៩៩ | ២៩ | 0,៧១ | ២ | 0,0៤ |
| សីហា | ៤.១០៤ | ៤.១១៥ | ៤.១១០ | ៧ | 0,១៧ | ៤.១០៧ | ៨ | 0,២0 | -៥ | -0,១២ |
| កញ្ញា | ៤.១១៧ | ៤.១២៦ | ៤.១២២ | ១៣ | 0,៣២ | ៤.១១៩ | ១២ | 0,២៩ | -១ | -0,0២ |
| តុលា | ៤.១៣៥ | ៤.១៤៥ | ៤.១៤០ | ១៨ | 0,៤៤ | ៤.១៤១ | ២២ | 0,៥៣ | -១ | -0,0២ |
| វិច្ឆិកា | ៤.១១០ | ៤.១២០ | ៤.១១៥ | -២៥ | -0,៦0 | ៤.១២២ | -១៩ | -0,៤៦ | ២ | 0,0៤ |
| ធ្នូ | ៤.១១៣ | ៤.១២៣ | ៤.១១៨ | ៣ | 0,0៧ | ៤.១១៧ | -៥ | -0,១២ | ១ | 0,0១ |
| **២០២៣** | | | | | | | | | | |
| មករា | ៤.១០២ | ៤.១១៣ | ៤.១០៨ | -១១ | -0,២៧ | ៤.១០៤ | -១៣ | -0,៣២ | ២ | 0,0៤ |
| កុម្ភៈ | ៤.០៥០ | ៤.០៦៣ | ៤.០៥៧ | -៥២ | -១,២៧ | ៤.០៤៣ | -៦១ | -១,៤៩ | ៣ | 0,១0 |
| មីនា | ៤.០៥១ | ៤.០៦២ | ៤.០៥៧ | ១ | 0,0២ | ៤.០៥៤ | ១១ | 0,២៧ | ៥ | 0,១១ |
| មេសា | ៤.១១៤ | ៤.១២៦ | ៤.១២០ | ៦៣ | ១,៥៦ | ៤.១១៥ | ៦១ | ១,៥0 | ៥ | 0,១២ |
| ឧសភា | ៤.១១៦ | ៤.១២៦ | ៤.១២១ | ២ | 0,0៥ | ៤.១១៦ | ១ | 0,0២ | ១ | 0,0២ |
| មិថុនា | ៤.១២៦ | ៤.១៣៦ | ៤.១៣១ | ១0 | 0,២៤ | ៤.១៣0 | ១៤ | 0,៣៤ | ១ | 0,0១ |
| កក្កដា | ៤.១២៤ | ៤.១៣៤ | ៤.១២៩ | -២ | -0,0៥ | ៤.១៣0 | 0 | 0,00 | -១ | -0,0២ |
| សីហា | ៤.១៥១ | ៤.១៦១ | ៤.១៥៦ | ២៧ | 0,៦៥ | ៤.១៥៨ | ២៨ | 0,៦៨ | -៣ | -0,0៦ |
| កញ្ញា | ៤.១១៩ | ៤.១៣០ | ៤.១២៥ | -៣២ | -0,៧៧ | ៤.១២២ | -៣៦ | -0,៨៧ | ៣ | 0,0៦ |
| តុលា | ៤.១២៩ | ៤.១៣៧ | ៤.១៣៣ | ១0 | 0,២៤ | ៤.១៣៥ | ១៣ | 0,៣២ | ២ | 0,0៥ |
| វិច្ឆិកា | ៤.១១៣ | ៤.១២៣ | ៤.១១៨ | -១៦ | -0,៣៩ | ៤.១១៥ | -២0 | -0,៤៨ | ២ | 0,0៤ |
| ធ្នូ | ៤.០៨០ | ៤.០៩០ | ៤.០៨៥ | -៣៣ | -0,៨0 | ៤.០៨៥ | -៣0 | -0,៧៣ | 0 | 0,00 |
| **២០២៤** | | | | | | | | | | |
| មករា | ៤.០៨០ | ៤.០៩១ | ៤.០៨៦ | 0 | -0,៥៤ | ៤.០៨៣ | -២ | -0,0៥ | -១ | 0,0២ |
| កុម្ភៈ | ៤.០៦៤ | ៤.០៧៣ | ៤.០៦៩ | -១៦ | 0,៣៥ | ៤.០៦៩ | -១៤ | -0,៣៤ | ២ | 0,0៤ |
| មីនា | ៤.០៤០ | ៤.០៤៩ | ៤.០៤៥ | -២៤ | -0,២៧ | ៤.០៤១ | -២៨ | -0,៦៩ | ៤ | 0,0៩ |

# MONTHLY EXCHANGE RATE

(End-Month)

| End month | Parallel Market Rate | | | | | Official Exchange Rate | | | Spread | |
|---|---|---|---|---|---|---|---|---|---|---|
| | Purchase | Sale | Midpoint | Monthly Change | | Midpoint | Monthly Change | | Official-Market | |
| | | | | +/- | % | | +/- | % | +/- | % |
| **2021** | | | | | | | | | | |
| April | 4,068 | 4,083 | 4,076 | 6 | 0.15 | 4,048 | 3 | 0.07 | 28 | 0.68 |
| May | 4,107 | 4,116 | 4,112 | 39 | 0.96 | 4,072 | 24 | 0.59 | 37 | 0.90 |
| June | 4,102 | 4,112 | 4,107 | -5 | -0.12 | 4,075 | 3 | 0.07 | 29 | 0.71 |
| July | 4,107 | 4,117 | 4,112 | 5 | 0.12 | 4,072 | -3 | -0.07 | 40 | 0.98 |
| August | 4,119 | 4,129 | 4,124 | 12 | 0.29 | 4,080 | 8 | 0.20 | 44 | 1.04 |
| September | 4,119 | 4,130 | 4,125 | 0 | 0.00 | 4,079 | -1 | -0.02 | 44 | 1.08 |
| October | 4,099 | 4,109 | 4,104 | -20 | -0.49 | 4,066 | -13 | -0.32 | 37 | 0.90 |
| November | 4,102 | 4,113 | 4,108 | 3 | 0.07 | 4,069 | 3 | 0.07 | 36 | 0.88 |
| December | 4,109 | 4,118 | 4,114 | 7 | 0.17 | 4,074 | 5 | 0.12 | 40 | 0.97 |
| **2022** | | | | | | | | | | |
| January | 4,088 | 4,098 | 4,093 | -21 | -0.51 | 4,066 | -8 | -0.20 | 27 | 0.65 |
| February | 4,086 | 4,094 | 4,095 | -2 | -0.05 | 4,066 | 0 | 0.00 | 25 | 0.60 |
| March | 4,068 | 4,078 | 4,073 | -18 | -0.44 | 4,050 | -16 | -0.39 | 23 | 0.56 |
| April | 4,068 | 4,080 | 4,074 | 0 | 0.00 | 4,046 | -4 | -0.10 | 28 | 0.69 |
| May | 4,088 | 4,097 | 4,093 | 20 | 0.49 | 4,062 | 16 | 0.40 | 31 | 0.75 |
| June | 4,091 | 4,100 | 4,096 | 3 | 0.07 | 4,070 | 8 | 0.20 | 22 | 0.54 |
| July | 4,097 | 4,104 | 4,101 | 6 | 0.15 | 4,099 | 29 | 0.71 | 2 | 0.04 |
| August | 4,104 | 4,115 | 4,110 | 7 | 0.17 | 4,107 | 8 | 0.20 | -5 | -0.12 |
| September | 4,117 | 4,126 | 4,122 | 13 | 0.32 | 4,119 | 12 | 0.29 | -1 | -0.02 |
| October | 4,135 | 4,145 | 4,140 | 18 | 0.44 | 4,141 | 22 | 0.53 | -1 | -0.02 |
| November | 4,110 | 4,120 | 4,115 | -25 | -0.60 | 4,122 | -19 | -0.46 | 2 | 0.04 |
| December | 4,113 | 4,123 | 4,118 | 3 | 0.07 | 4,117 | -5 | -0.12 | 1 | 0.01 |
| **2023** | | | | | | | | | | |
| January | 4,102 | 4,113 | 4,108 | -11 | -0.27 | 4,104 | -13 | -0.32 | 2 | 0.04 |
| February | 4,050 | 4,063 | 4,057 | -52 | -1.27 | 4,043 | -61 | -1.49 | 3 | 0.10 |
| March | 4,051 | 4,062 | 4,057 | 1 | 0.02 | 4,054 | 11 | 0.27 | 5 | 0.11 |
| April | 4,114 | 4,126 | 4,120 | 63 | 1.56 | 4,115 | 61 | 1.50 | 5 | 0.12 |
| May | 4,116 | 4,126 | 4,121 | 2 | 0.05 | 4,116 | 1 | 0.02 | 1 | 0.02 |
| June | 4,126 | 4,136 | 4,131 | 10 | 0.24 | 4,130 | 14 | 0.34 | 1 | 0.01 |
| July | 4,124 | 4,134 | 4,129 | -2 | -0.05 | 4,130 | 0 | 0.00 | -1 | -0.02 |
| August | 4,151 | 4,161 | 4,156 | 27 | 0.65 | 4,158 | 28 | 0.68 | -3 | -0.06 |
| September | 4,119 | 4,130 | 4,125 | -32 | -0.77 | 4,122 | -36 | -0.87 | 3 | 0.06 |
| October | 4,129 | 4,137 | 4,133 | 10 | 0.24 | 4,135 | 13 | 0.32 | 2 | 0.05 |
| November | 4,113 | 4,123 | 4,118 | -16 | -0.39 | 4,115 | -20 | -0.48 | 2 | 0.04 |
| December | 4,080 | 4,090 | 4,085 | -33 | -0.80 | 4,085 | -30 | -0.73 | 0 | 0.00 |
| **2024** | | | | | | | | | | |
| January | 4,080 | 4,091 | 4,086 | 0.0 | 0.00 | 4,083 | -2 | -0.05 | -1 | -0.02 |
| February | 4,064 | 4,073 | 4,069 | -16.0 | -0.39 | 4,069 | -14 | -0.34 | 2 | 0.04 |
| March | 4,040 | 4,049 | 4,045 | -24.0 | -0.59 | 4,041 | -28 | -0.69 | 4 | 0.09 |

# ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ

| | មករា-២៤ | | កុម្ភៈ-២៤ | | មីនា-២៣ | |
|---|---|---|---|---|---|---|
| | ប៊ីលានរៀល | % | ប៊ីលានរៀល | % | ប៊ីលានរៀល | % |
| **ប្រាក់បញ្ញើជារៀល** | | | | | | |
| ប្រាក់បញ្ញើចរន្ត | ៤.៤៥០,៥ | ១,៦ | ៤.៥៣១,១ | ១,៨ | ៤.៦៩១,៩ | ៣,៥ |
| ប្រាក់បញ្ញើសន្សំ | ៤.១៧៩,៦ | -១,៩ | ៤.២៨៤,៨ | ២,៥ | ៤.២៤២,៨ | -១,០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១២.៦០៩,៥ | ១,៩ | ១២.៦៣០,១ | ០,២ | ១២.២៩១,៨ | -២,៧ |
| ប្រាក់បញ្ញើផ្សេងៗ | ៤១០,១ | -០,៤ | ៤២៥,៧ | ៣,៨ | ៤១៦,៧ | -២,១ |
| **សរុប** | **២១.៦៤៩,៧** | **១,០** | **២១.៨៧១,៦** | **១,០** | **២១.៦៤៣,២** | **-១,០** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | | |
| ប្រាក់បញ្ញើចរន្ត | ២៧.៤៣៣,៤ | -០,១ | ២៨.៧០៨,៧ | ៤,៦ | ២៨.៧៦២,៣ | ០,២ |
| ប្រាក់បញ្ញើសន្សំ | ៤២.០៥២,៩ | ០,៦ | ៤២.២៣៣,៣ | ០,៤ | ៤៣.៣៨២,៨ | ២,៧ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៩៦.៤៤៦,៨ | ២,០ | ៩៧.៧២៥,៣ | ១,៣ | ៩៨.៨០២,១ | ១,១ |
| ប្រាក់បញ្ញើផ្សេងៗ | ២.៨៤៦,១ | -០,២ | ២.៨៦០,៩ | ០,៥ | ២.៩០៥,២ | ១,៥ |
| **សរុប** | **១៦៨.៧៧៩,២** | **១,៣** | **១៧១.៥២៨,២** | **១,៦** | **១៧៣.៨៥២,៤** | **១,៤** |
| **សរុបរួម** | **១៩០.៤២៨,៩** | **១,៣** | **១៩៣.៣៩៩,៨** | **១,៦** | **១៩៥.៤៩៥,៦** | **១,១** |

## DEPOSITS WITH DEPOSIT MONEY BANKS AND MONTHLY CHANGE

| | Jan-24 | | Feb-24 | | Mar-24 | |
|---|---|---|---|---|---|---|
| | KHR. Billion | % | KHR. Billion | % | KHR. Billion | % |
| DEPOSITS IN KHR. | | | | | | |
| Demand deposits | 4,450.5 | 1.6 | 4,531.1 | 1.8 | 4,691.9 | 3.5 |
| Savings deposits | 4,179.6 | -1.9 | 4,284.8 | 2.5 | 4,242.8 | -1.0 |
| Fixed deposits | 12,609.5 | 1.9 | 12,630.1 | 0.2 | 12,291.8 | -2.7 |
| Others | 410.1 | -0.4 | 425.7 | 3.8 | 416.7 | -2.1 |
| **Total** | **21,649.7** | **1.0** | **21,871.6** | **1.0** | **21,643.2** | **-1.0** |
| DEPOSITS IN FOREIGN CURRENCY | | | | | | |
| Demand deposits | 27,433.4 | -0.1 | 28,708.7 | 4.6 | 28,762.3 | 0.2 |
| Savings deposits | 42,052.9 | 0.6 | 42,233.3 | 0.4 | 43,382.8 | 2.7 |
| Fixed deposits | 96,446.8 | 2.0 | 97,725.3 | 1.3 | 98,802.1 | 1.1 |
| Others | 2,846.1 | -0.2 | 2,860.9 | 0.5 | 2,905.2 | 1.5 |
| **Total** | **168,779.2** | **1.3** | **171,528.2** | **1.6** | **173,852.4** | **1.4** |
| **GRAND TOTAL** | **190,428.9** | **1.3** | **193,399.8** | **1.6** | **195,495.6** | **1.1** |

# ឥណទានផ្តល់ដោយធនាគារទទួលប្រាក់បញ្ញើតាមប្រភេទជំនួញ និងបម្រែបម្រួលប្រចាំខែ

| | មករា-២៤ | | កុម្ភៈ-២៤ | | មីនា-២៤ | |
|---|---|---|---|---|---|---|
| | ប៊ីលានរៀល | % | ប៊ីលានរៀល | % | ប៊ីលានរៀល | % |
| **គ្រឹះស្ថានហិរញ្ញវត្ថុ** | **៧.៥២៥,៥** | **-៣,៩** | **៧.៣៦៩,០** | **-២,១** | **៧.០២១,៩** | **-៤,៧** |
| ធនាគារជាតិនៃកម្ពុជា | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៥.៧២៧,៩ | -៤,២ | ៥.៥៩៤,២ | -២,៣ | ៥.២៥៥,៤ | -៦,១ |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១.៧៩៧,៦ | -៣,១ | ១.៧៧៤,៧ | -១,៣ | ១.៧៦៦,៦ | -០,៥ |
| **គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ** | **១៦១.៨៧៦,៥** | **០,៦** | **១៦១.៤២៦,២** | **-០,៣** | **១៦០.៨៩៣,៩** | **-០,៣** |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៩.៣៣៩,៣ | ០,៥ | ១៩.២៥០,៧ | -០,៥ | ១៩.០៩៥,៨ | -០,៨ |
| ឧស្សាហកម្មរ៉ែ | ១.១០៦,០ | ១,៦ | ១.១៣៥,៣ | ២,៧ | ១.១៥៣,៩ | ១,៦ |
| កម្មន្តសាលកម្ម | ៩.៤៩៤,៥ | ១,៧ | ៩.៤៤៧,៧ | -០,៥ | ៩.៣៨០,៥ | -០,៧ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ២.៤០៥,៣ | -០,៤ | ២.៤៨៩,៣ | ៣,៥ | ២.៥០៣,៧ | ០,៦ |
| សំណង់ | ២០.៤៣១,៧ | -១,៩ | ២០.៤៣៦,៦ | ០,០ | ២០.៦០០,១ | ០,៨ |
| ការជួញដូរដុំ | ១៨.៩៦១,១ | -១,៦ | ១៨.៩៥១,៩ | ០,០ | ១៨.៦២៩,១ | -១,៧ |
| ការជួញដូររាយ | ៣៧.៣៥២,៤ | ០,៥ | ៣៧.៣៣៦,៨ | ០,០ | ៣៧.០៤៩,៤ | -០,៨ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៨.៤៥០,៨ | ០,៥ | ៨.១៣៦,៧ | -៣,៧ | ៨.១២០,៨ | -០,២ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ៦.៤៣៣,៧ | ៦,២ | ៦.៣៥៥,៣ | -១,២ | ៦.៣១០,៨ | -០,៧ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ១.០៩២,៧ | ១,៨ | ១.០២៩,៥ | -៥,៨ | ១.០៥៩,៣ | ២,៩ |
| អាជីវកម្មជួលនិងភតិសន្យា(មិនរាប់បញ្ចូលភតិសន្យានិងការជួលអចលនទ្រព្យ) | ២.៨៤៦,៤ | -០,៣ | ២.៩២០,១ | ២,៦ | ២.៨៦២,៣ | -២,០ |
| ការជួញដូរអចលនទ្រព្យ | ២២.៨៦៧,៧ | ៣,១ | ២២.៨២១,៩ | -០,២ | ២៣.៣៤០,៣ | ២,៣ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | ១១.០៩៤,៨ | ១,១ | ១១.១១៤,៣ | ០,២ | ១០.៧៨៨,០ | -២,៩ |
| **ឥណទានការផ្ទាល់ខ្លួន** | **៤៨.៥២១,៣** | **-២,៤** | **៤៨.៦៦៦,០** | **០,៣** | **៤៨.៩៨១,៤** | **០,៦** |
| ការឱ្យខ្ចីជាបុគ្គល | ២០.០២៣,៧ | -២,៥ | ២០.៣៣៩,៩ | ១,៦ | ២០.៨៤៥,៨ | ២,៥ |
| ការឱ្យខ្ចីតាមប័ណ្ណឥណទាន | ៧២៩,៧ | ២,៩ | ៧២០,៧ | -១,២ | ៧៣៣,៦ | ១,៨ |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ២៧.៧៦៨,០ | -២,៤ | ២៧.៦០៥,៤ | -០,៦ | ២៧.៤០២,០ | -០,៧ |
| **ឥណទានផ្សេងៗ** | **២.៩២៦,៧** | **៦,៣** | **២.៩៦២,២** | **១,២** | **២.៩៣០,៥** | **-១,១** |
| **សរុបឥណទានដុល** | **២២០.៨៥០,១** | **-០,២** | **២២០.៤២៣,៣** | **-០,២** | **២១៩.៨២៧,៧** | **-០,៣** |

# CREDIT GRANTED BY DEPOSIT MONEY BANKS CLASSIFIED BY INDUSTRY AND MONTHLY CHANGE

| | Jan-24 | | Feb-24 | | Mar-24 | |
|---|---|---|---|---|---|---|
| | KHR. Billion | # | KHR. Billion | # | KHR. Billion | # |
| **FINANCIAL IN STITUTIONS** | **7,525.5** | **-3.9** | **7,369.0** | **-2.1** | **7,021.9** | **-4.7** |
| National Bank of Cambodia | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| Depository Institutions | 5,727.9 | -4.2 | 5,594.2 | -2.3 | 5,255.4 | -6.1 |
| Other Financial Institutions | 1,797.6 | -3.1 | 1,774.7 | -1.3 | 1,766.6 | -0.5 |
| **NON-FINANCIAL INSTITUTIONS** | **161,876.5** | **0.6** | **161,426.2** | **-0.3** | **160,893.9** | **-0.3** |
| Agriculture, Forestry and Fishing | 19,339.3 | 0.5 | 19,250.7 | -0.5 | 19,095.8 | -0.8 |
| Mining and Quarrying | 1,106.0 | 1.6 | 1,135.3 | 2.7 | 1,153.9 | 1.6 |
| Manufacturing | 9,494.5 | 1.7 | 9,447.7 | -0.5 | 9,380.5 | -0.7 |
| Utilities | 2,405.3 | -0.4 | 2,489.3 | 3.5 | 2,503.7 | 0.6 |
| Construction | 20,431.7 | -1.9 | 20,436.6 | 0.0 | 20,600.1 | 0.8 |
| Wholesale Trade | 18,961.1 | -1.6 | 18,951.9 | 0.0 | 18,629.1 | -1.7 |
| Retail Trade | 37,352.4 | 0.5 | 37,336.8 | 0.0 | 37,049.4 | -0.8 |
| Hotels and Restaurants | 8,450.8 | 0.5 | 8,136.7 | -3.7 | 8,120.8 | -0.2 |
| Transport and Storage | 6,433.7 | 6.2 | 6,355.3 | -1.2 | 6,310.8 | -0.7 |
| Information Media and Telecommunications | 1,092.7 | 1.8 | 1,029.5 | -5.8 | 1,059.3 | 2.9 |
| Rental and Operational Leasing Activities | 2,846.4 | -0.3 | 2,920.1 | 2.6 | 2,862.3 | -2.0 |
| Real Estate Activities | 22,867.7 | 3.1 | 22,821.9 | -0.2 | 23,340.3 | 2.3 |
| Other Financial Services | 11,094.8 | 1.1 | 11,114.3 | 0.2 | 10,788.0 | -2.9 |
| **PERSONAL ESSENTIALS** | **48,521.3** | **-2.4** | **48,666.0** | **0.3** | **48,981.4** | **0.6** |
| Personal Lending | 20,023.7 | -2.5 | 20,339.9 | 1.6 | 20,845.8 | 2.5 |
| Credit Card | 729.7 | 2.9 | 720.7 | -1.2 | 733.6 | 1.8 |
| Mortgages, Owner-Occupied Housing only | 27,768.0 | -2.4 | 27,605.4 | -0.6 | 27,402.0 | -0.7 |
| **OTHER LENDING** | **2,926.7** | **6.3** | **2,962.2** | **1.2** | **2,930.5** | **-1.1** |
| **TOTAL GROSS LOAN** | **220,850.1** | **-0.2** | **220,423.3** | **-0.2** | **219,827.7** | **-0.3** |

# ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការមិនមែនរដ្ឋាភិបាល

| | មករា-២៤ | កុម្ភៈ-២៤ | មីនា-២៤ |
|---|---|---|---|
| ចំនួនការិយាល័យកណ្តាល | ៨៧ | ៨៧ | ៨៧ |
| ចំនួនសាខាខេត្ត / ក្រុង | ៣១១ | ៣១០ | ៣០៨ |
| ចំនួនសាខាស្រុក / ខណ្ឌ | ៥១៦ | ៥១៤ | ៥១៣ |
| ចំនួនអ្នកស្នើសុំឥណទាន | ១.៦១៩.០២២ | ១.៦១៧.៤៦៦ | ១.៦១៤.៥៤៨ |
| ប្រាក់កម្ចី (គិតជាប៊ីលានរៀល) | ២១.០៨៦ | ២១.០៦៥ | ២០.៩៧៣ |
| អត្រាការប្រាក់ប្រចាំខែ | ១,០%-១,៥% | ១,០%-១,៥% | ១,០%-១,៥% |
| អត្រាការប្រាក់ប្រចាំឆ្នាំ | ១២,១%-១៨,១% | ១២,១%-១៨,១% | ១១,៩%-១៨,១% |

# CREDIT GRANTED BY MICRO-FINANCE INSTITUTIONS AND NON-GOVERNMENT ORGANIZATIONS

| | Jan-24 | Feb-24 | Mar-24 |
|---|---|---|---|
| Number of Head Office | 87 | 87 | 87 |
| Number of Branches in Province / Krong | 311 | 310 | 308 |
| Number of Branches in District / Khan | 516 | 514 | 513 |
| Number of Borrowers | 1,619,022 | 1,617,466 | 1,614,548 |
| Loan Outstanding (In KHR Billion) | 21,086 | 21,065 | 20,973 |
| Monthly Interest Rate | 1.0%-1.5% | 1.0%-1.5% | 1.0%-1.5% |
| Annually Interest Rate | 12.1%-18.1% | 12.1%-18.1% | 11.9%-18.1% |

# ការផាត់ទាត់មូលប្បទានបត្រតាមរយៈសភាផាត់ទាត់

| | មករា-២៤ | កុម្ភៈ-២៤ | មីនា-២៣ | សរុប |
|---|---|---|---|---|
| **មូលប្បទានបត្រ ជារូបិយប្រាក់រៀល** | | | | |
| ចំនួនថ្ងៃផាត់ទាត់ | ២២ | ២១ | ២០ | ៦៣ |
| ចំនួនមូលប្បទានបត្របានទូទាត់ | ២.៧០៦ | ២.៨៥៩ | ២.៨៨២ | ៨.៤៤៧ |
| ចំនួនទឹកប្រាក់សរុប (ប៊ីលានរៀល) | ១.៨៦៧,៤ | ១.៤១០,៩ | ២.០១៩,៤ | ៥.២៩៧,៧ |
| ចំនួនមូលប្បទានបត្របានទូទាត់ក្នុងថ្ងៃ | ១២៣ | ១៣៦ | ១៤៤ | ១៣៤ |
| ទឹកប្រាក់ជាមធ្យមប្រចាំថ្ងៃ (ប៊ីលានរៀល) | ៨៤,៩ | ៦៧,២ | ១០១,០ | ៨៤,១ |
| ចំនួនមូលប្បទានបត្របញ្ជូនត្រឡប់ | ៦ | ៨ | ៨ | ២២ |
| ជាទឹកប្រាក់បញ្ជូនត្រឡប់សរុប (ប៊ីលានរៀល) | ៥,៨ | ៣,៥ | ១,៦ | ១០,៩ |
| **មូលប្បទានបត្រ ជារូបិយប្រាក់ដុល្លារអាមេរិក** | | | | |
| ចំនួនថ្ងៃផាត់ទាត់ | ២២ | ២១ | ២០ | ៦៣ |
| ចំនួនមូលប្បទានបត្របានទូទាត់ | ៨៩.៨៤៥ | ៧៩.១៦១ | ៨៣.០៦១ | ២៥២.០៦៧ |
| ចំនួនទឹកប្រាក់សរុប (លានដុល្លារអាមេរិក) | ៣.៩២៩,៣ | ៣.៥០៤,៧ | ៣.៩៣៩,២ | ១១.៣៧៣,២ |
| ចំនួនមូលប្បទានបត្របានទូទាត់ក្នុងថ្ងៃ | ៤.០៨៤ | ៣.៧៧០ | ៤.១៥៣ | ៥.៨៦២ |
| ទឹកប្រាក់ជាមធ្យមប្រចាំថ្ងៃ (លានដុល្លារអាមេរិក) | ១៧៨,៦ | ១៦៦,៩ | ១៩៧,០ | ២៦៤,៥ |
| ចំនួនមូលប្បទានបត្របញ្ជូនត្រឡប់ | ៩០៧ | ៨៦៥ | ៧៩៥ | ២.៥៦៧ |
| ទឹកប្រាក់បញ្ជូនត្រឡប់សរុប (លានដុល្លារអាមេរិក) | ២០៥,៦ | ៤៩,៧ | ៦០,១ | ៣១៥,៤ |

## CHECKS CLEARING THROUGH CLEARING HOUSE

| | Jan-24 | Feb-24 | Mar-24 | Total |
|---|---|---|---|---|
| **KHR-DENOMINATED CHECKS CLEARING** | | | | |
| Number of Working Day | 22 | 21 | 20 | 63 |
| Number of Checks Cleared | 2,706 | 2,859 | 2,882 | 8,447 |
| Total Amount (In KHR Billion) | 1,867.4 | 1,410.9 | 2,019.4 | 5,297.7 |
| Number of Checks Cleared Per Day | 123 | 136 | 144 | 134 |
| Daily Average Amount (In KHR Billion) | 84.9 | 67.2 | 101.0 | 84.1 |
| Number of Checks Returned | 6 | 8 | 8 | 22 |
| Amounts of Checks Returned (In KHR Billion) | 5.83 | 3.51 | 1.60 | 10.94 |
| **USD-DENOMINATED CHECKS CLEARING** | | | | |
| Number of Working Day | 22 | 21 | 20 | 63 |
| Number of Checks Cleared | 89,845 | 79,161 | 83,061 | 252,067 |
| Total Amount (In USD Million) | 3,929.3 | 3,504.7 | 3,939.2 | 11,373.2 |
| Number of Checks Cleared Per Day | 4,084 | 3,770 | 4,153 | 5,862 |
| Daily Average Amount (In USD Million) | 178.6 | 166.9 | 197.0 | 264.5 |
| Number of Checks Returned | 907 | 865 | 795 | 2,567 |
| Amounts of Checks Returned (In USD Million) | 205.6 | 49.7 | 60.1 | 315.4 |

# ប្រព័ន្ធធនាគារកម្ពុជា (ខែមីនា ឆ្នាំ២០២៤)

## ធនាគារជាតិនៃកម្ពុជា

### ៥៩ ធនាគារពាណិជ្ជ

**២៨ បង្កើតក្នុងស្រុក**

១ ព.ណ.ក្រៅប្រទេស
២ កម្ពុជាអាស៊ី
៣ កាណាឌីយ៉ា
៤ ធនាគារវឌ្ឍនៈ
៥ អេស៊ីលីដា
៦ ស្ថាបនា
៧ ប៊ូយ៉ុងខ្មែរ
៨ ភ្នំពេញពាណិជ្ជ
៩ ប្រៃសណីយ៍
១០ ឈីហ្វ
១១ ប៊ី.អាយ.ស៊ី
១២ ព្រីនស៍
១៣ ជីបម៉ុង
១៤ អេស៊ា-ប៉ាស៊ីហ្វិក
១៥ ផេនដា ខមមើសល
១៦ អភិ.ជនបទ និងកសិ.
១៧ សហ. ធុនតូចនិងមធ្យម
១៨ ពាណិជ្ជ អាល់ហ្វា
១៩ អេសប៊ីអាយលីហ្សរ
២០ ធនាគារហត្ថា
២១ រួយលី
២២ វីង
២៣ ហេងហ៊ី
២៤ អូរៀនថល
២៥ ប្រ៊ីដ
២៦ ស៊ីស៊ីយូ
២៧ ហេង ហ្វឹង
២៨ អាយភីយូ

**១១ សាខាបរទេស**

១ ធ.ពាណិជ្ជទី១
២ ធ.ក្រុងថៃ
៣ ធនាគារចិន
៤ ធនាគារមេហ្គា
៥ អាយស៊ីប៊ីស៊ី
៦ ធនាគារតៃវ៉ាន់
៧ ធនាគារបាងកក
៨ ធនាគារកសិកន
៩ ធនាគារមីហ្សូហូ
១០ ធ. វៀតណាម
១១ អ៊ិនដាសស្រៀល

**២០ បុត្តសម្ព័ន្ធ**

១ កម្ពុជាពាណិជ្ជ
២ សាធារណៈ
៣ មេយប៊ែង
៤ ជេ ត្រាស់ រ៉ូយ៉ាល់
៥ វឌ្ឍនៈអាស៊ី
៦ វិនិយោគ និងអភិ.
៧ ស៊ិនហានខ្មែរ
៨ អ អេច ប៊ី
៩ ស៊ីអាយ អឹមប៊ី
១០ សាខម ប៊ែង
១១ ហុងលីអ៊ុង
១២ ធនាគារកាថេ
១៣ សហពាណិជ្ជ
១៤ ហ្វីលីព
១៥ សៃហ្គន-ហាណូយ
១៦ ប្រេដប៊ែង
១៧ ឌីជីប៊ី
១៨ ធនាគារ អ៊ូរី
១៩ ធនាគារ អ៊ឹមប៊ី
២០ ខេប៊ីប្រាសាក់

### ៩ ធនាគារឯកទេស

**៤ បង្កើតឡើងក្នុងស្រុក**

១ អានកូ
២ អេវើហ្គ្រស៍
៣ ឯកទេស ម៉ារីថាម
៤ ដូនពេញ

**៥ ធនាគារបរទេស**

១ ភីអេចអេសអឹមអ៊ី
២ ខេប៊ី ដេហាន
៣ អង្គរកាពីតាល់
៤ អ៊ីអន
៥ សាវធើន យែភីថល

### ៥ ការិយាល័យតំណាង

១ ស្តង់ដារឆាទើរែត
២ ធ.វិ.អ.វៀតណាម
៣ ធ.ស៊ូមីតូម៉ូមីតស៊ុយ
៤ ធនាគារ សៀងហៃ
៥ អិចផត-អ៊ីមផត ប៊ែង

### ២០១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ

**៤ ទទួលប្រាក់បញ្ញើ**

១ អម្រឹត ម.ក
២ អេ អឹម ខេ
៣ អិល អូ អិល ស៊ី
៤ មហានគរ ម.ក

**៨៣ ផ្តល់ឥណទាន**

១ សីលានិធិ
២ វែលខម
៣ មាក់ស៊ីម៉ា
៤ ពលរដ្ឋរុងរឿង
៥ ណុងហឹប
៦ ហ្វាមើរ
៧ ហ្វឹស
៨ វ៉ាយស៊ុភី
៩ សំរិទ្ធិស័ក
១០ ខេមា
១១ ខេមរៈ
១២ ប្រាយ៍ម
១៣ សូណាត្រា
១៤ ចម្រើន
១៥ អាក់ទីវភីភល
១៦ បាយ៉ន
១៧ បរិបូរណ៍
១៨ យ៉្វីន
១៩ ស៊ីធី
២០ អមតៈ
២១ សច្ចៈ
២២ អ្សូរ៉
២៣ និរន្តរ
២៤ ខ្មែលតា
២៥ សេនជូរី
២៦ ប៊ីអេអឹមស៊ី
២៧ ពិភពថ្មី
២៨ សិរីឧត្តម
២៩ សម្បត្តិ
៣០ ប៊ីអេនខេស៊ី
៣១ ប៊ែមប៊ូ
៣២ សហគ្រិនភាព
៣៣ ឆាយលីស
៣៤ ធីប៊ីប៊ី
៣៥ រ៉ូយ៉ាល់
៣៦ សាន់នី
៣៧ ហ្វូណន
៣៨ សម្ព័ន្ធសហគ្រាស
៣៩ សាមគ្គី
៤០ ខេមបូឌា ឡេប៊ី
៤១ ខេម ខាប់ភីថល
៤២ គង្គា យែភីថល
៤៣ ហ្វូតាបា
៤៤ អ៊ីខ្មែមីតស៊ុ
៤៥ ម៉ាខ្មែរ
៤៦ សហការ
៤៧ ហ្គោលដិន
៤៨ ជោគជ័យ
៤៩ សប្បាយ
៥០ ជេត យែស
៥១ លីដ
៥២ អិល ប៊ី ភី
៥៣ ប្រសិទ្ធភាព
៥៤ ធី & ហ្វ
៥៥ អនាគត
៥៦ ហ្វ្រូវ
៥៧ បៃតង
៥៨ មីយ៉ា
៥៩ ឡេង ណាវ៉ាត្រា
៦០ វិថី
៦១ ទ្រព្យខ្ញុំ
៦២ ខ្មែរ
៦៣ ភីជី
៦៤ ជេស៊ី
៦៥ ស៊ីអិមខេ
៦៦ រ៉ូល្យា
៦៧ អិលស៊ីអេច
៦៨ ហ្វាមីលី
៦៩ ប្រពៃ
៧០ ស៊ិកធីស៊ិកស៍
៧១ ជីប៊ី
៧២ អេវើហ្គ្រីន
៧៣ វ៉ាយអិលភី
៧៤ សារ៉ាត រុងរឿង
៧៥ មែងហ្គោ
៧៦ ខូរីច ម៉ាយក្រូហ្វាយ
៧៧ វិវឌ្ឍន៍ ហ្គោលឌិន
៧៨ សាយ ហូសថល
៧៩ សុខសាន្ត
៨០ អេអិមហ្សេត
៨១ ជេកស៍
៨២ អ៊ីស្ត មីក្រូ ម.ក
៨៣ វ៉ាហ្វូកូ

**១១៤ ឥណទានជនបទ**

១ ជូ ជីវ័ន
២ គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ
៣ បវរ
៤ ពាយ័ព្យ
៥ សេន
៦ មិត្តភាព ហ្វាយនែន
៧ អិល អ៊ី ឌី អេ យែភីថល
៨ លីដ-ធី អាយ ភី អេស
៩ ដៃគូ
១០ ព្រះខ័ន អភិវឌ្ឍន៍
១១ ក្រេប៉ូ ហ្វាយនែន
១២ វី.ភី ឌិច
១៣ សិរីសួស្តី
១៤ អូស៊ីដាហ្វ
១៥ ជ ម៉ីជីង
១៦ ហ៊ីគាន
១៧ កូនខ្មែរមង្គលហិរញ្ញវត្ថុ
១៨ មានជ័យ
១៩ ប្រសើរ
២០ មាគ៌ា
២១ ខេភីស៊ីអេ
២២ ដាកូ
២៣ សំណាងប្រតិបត្តិការ
២៤ ស្នាយល៍ យែភីថល
២៥ គុណភាព
២៦ សំរឹទ្ធិ ពេជ្រ
២៧ ប៊ី.វ៉ាយ.ជី
២៨ យ៉្វីក អមតៈ
២៩ អិលអេច
៣០ បៃតង
៣១ ខេ.ឌី.អូ
៣២ ជុំ សំណាង
៣៣ ខេម
៣៤ ឥណទាន អ៊ីហ្សី
៣៥ ក្រុងខ្មែរ ហ្វាយនែន
៣៦ មរតក អភិវឌ្ឍន៍
៣៧ កល្យាណ អភិវឌ្ឍន៍
៣៨ ភូមិន្ទ
៣៩ វីរៈបុត្រ
៤០ ពន្លឺកសិករខ្មែរ ភី
៤១ ឥណទាន ជនបទខ្មែរ
៤២ អេស អេច ជី
៤៣ អរ អេន ឌី ប៊ី
៤៤ ផ្កាឈូក
៤៥ សុខសប្បាយ
៤៦ ខេ.ខេ.ស៊ី.អិម
៤៧ វ៉ាដូជីកូ
៤៨ ប្រសិទ្ធិភាព
៤៩ ហ្គូបល ឡែនឌីង ឮ
៥០ អិល ឌី អេ
៥១ ឥណទាននារី
៥២ ពិជោរ
៥៣ ស្តាយ ឡាយ
៥៤ តារា
៥៥ កូនកសិករ
៥៦ គ្រួសារឥណទាន
៥៧ អមតៈរុងរឿង
៥៨ ខ្មែរអង្គរ
៥៩ គន្ធាម
៦០ សំបូរណ៍
៦១ ទីបុត្តា
៦២ ស៊ី.ខេ
៦៣ វ៉ាយស្មាត
៦៤ សម្រឹត
៦៥ អង្គរ ឆព្វណ្ណ
៦៦ កាក់កប
៦៧ ស្នាយ
៦៨ សកល
៦៩ លើកស្ទួយ សមត្ថភាពគ្រួសារ
៧០ ព្រះច័ន្ទ
៧១ អូណ្ហ
៧២ យូនីដា
៧៣ អេហ្វអេចអេហ្វ
៧៤ ប្លូ
៧៥ ខេមរា
៧៦ ខេមហ្វាន់ ប្រាថ្នា
៧៧ អេអេហ្វជី
៧៨ ម៉ាមេឌី
៧៩ វីរៈស័ក
៨០ វ៉ាឆា
៨១ ឥណទានមូលដ្ឋាន
៨២ សម្របសម្រួល
៨៣ ពិស្ណុកា
៨៤ ប្រាក
៨៥ លីជូ
៨៦ អេ.លី.អិល.ភី.អិល
៨៧ ខេ អ៊ី ភី
៨៨ ពន្លឺស្នាមញញឹម
៨៩ រស្មីសិរីមង្គល
៩០ មេត្តា
៩១ អេហ្វធី យែស
៩២ រស្មីជ័យជំនះ
៩៣ រីករាយ
៩៤ ស៊ី.ខេ.អិល.អេស
៩៥ យូនីត្រាស់
៩៦ ជីប៊ីអាយធី
៩៧ ឥណទាន អភិវឌ្ឍន៍
៩៨ គ្រីស្គាល់
៩៩ អេស ប៊ី អី
១០០ ស៊ី.វី.អេ
១០១ អាខាបារ
១០២ រិទ្ធី
១០៣ សមធម៌
១០៤ ផាតនើរ
១០៥ រាហ៊ូ
១០៦ សុវណ្ណភូមិ សូសល
១០៧ ធិតិមា
១០៨ អេស.អិម.អ៊ី.អេស
១០៩ ផានីតដា
១១០ អូខិនជិន
១១១ វ៉ាយ ផ្លេស
១១២ ហ័ប ហ្វាន់
១១៣ មរកត
១១៤ វី ស៊ីវីស

### សាខាធនាគារជាតិនៃកម្ពុជា

១ ភ្នំពេញ
២ កំពង់ចាម
៣ ព្រះសីហនុ
៤ សៀមរាប
៥ បាត់ដំបង
៦ បន្ទាយមានជ័យ
៧ ស្វាយរៀង
៨ កណ្តាល
៩ កំពត
១០ កំពង់ធំ
១១ ពោធិ៍សាត់
១២ កំពង់ស្ពឺ
១៣ កោះកុង
១៤ រតនៈគិរី
១៥ ព្រៃវែង
១៦ តាកែវ
១៧ កំពង់ឆ្នាំង
១៨ ព្រះវិហារ
១៩ ក្រចេះ
២០ ស្ទឹងត្រែង
២១ មណ្ឌលគិរី

### អាជីវកម្មផ្សេងៗ

**អាជីវកម្មប្តូរប្រាក់: ៣.១៨៧**

| | |
|---|---|
| ភ្នំពេញ: | ៥៨ |
| • អាជ្ញាប័ណ្ណ: | ២១ |
| • លិខិតអនុញ្ញាត: | ៣៧ |
| ខេត្ត: | ៣.១២៩ |
| • អាជ្ញាប័ណ្ណ: | ១ |
| • លិខិតអនុញ្ញាត: | ៣.១២៨ |

**១៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ**

១ ជីអិល ហ្វាយនែន
២ ប៊ីអេសភី ហ្វាយនែន
៣ មេហ្គា លីស៊ីង
៤ សួស្តី ហ្វាយនែន
៥ ខេខេហ្វាន់ លីស៊ីង
៦ តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន
៧ ម៉ូប៊ីលីធី
៨ អាយ ហ្វាយនែន
៩ លីហ្សូរ លីស៊ីង
១០ ឆាយលីស រ៉ូយ៉ាល លីស៊ីង
១១ ខូម៉ាត់ស៊ុ លីស៊ីង
១២ គូបូតា លីស៊ីង
១៣ អិល អូ ឌី
១៤ អាយយែរ លីស៊ីង
១៥ ហ្វរវើដ លីស៊ីង
១៦ វី ស៊ីវីស លីស៊ីង

**៦ តតិយភាគី**

១ ក្រុមហ៊ុន Western Union
២ ក្រុមហ៊ុន Money Gram
៣ ក្រុមហ៊ុន Continental Exchange
៤ ក្រុមហ៊ុន Eurogiro A/S
៥ ក្រុមហ៊ុន Merchantrade Asia
៦ ក្រុមហ៊ុន ណូវើស ថេកណូឡូជី

**៣៣ គ្រឹះស្ថានផ្តល់សេវាទូទាត់**

១ ទ្រូ ម៉ាន់នី
២ លីហ្សូរ ផេ ប្រូ
៣ ផាយផេ
៤ អេស៊ា យែស
៥ ស៊ីធេល ហ្វាយនែនសល
៦ ស្ព៊ីត ផេ
៧ អាប៊ីត្រេរី ផេយ
៨ យូប៊ីល
៩ អ៊ីឌាល
១០ អាយផេ ៨៨
១១ បងឡូយ ផេម៉ិន
១២ ធានស៊ូ អ៊ិនធើណេសិនណល
១៣ ហួយ វ៉ន
១៤ អ៊ី-ម៉ាន់នី
១៥ ជ្រេហ្គនហ្វាយ
១៦ ដាយនែមីក
១៧ តារាសាគរ ផេ
១៨ បៃ សេន ថេកណូឡូជី
១៩ អ៊ែរទ្រីណូ គ្លូបល
២០ ផាវ៉ាហ្គន
២១ យេស អ៊ិននើវេសិន
២២ អិលអិម ផេ
២៣ វ៉ិន ផេ ម.ក
២៤ លីន ផេ
២៥ យូ-ផេ
២៦ ស្តារផេ
២៧ ឡានតុន
២៨ វីង ម៉ាន់នី
២៩ គ្លីក ផេម៉ិន
៣០ សាន់ផេ
៣១ កៃ ហ្វូ តុង ផេម៉ិន
៣២ ផេយ៉ុន
៣៣ ជីន ហុង ជិន

**១ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ**

១ ក្រេឌីតប្យូរ៉ូ (ខេមបូឌា)

# THE BANKING SYSTEM IN CAMBODIA (In March 2024)

## NATIONAL BANK OF CAMBODIA

### 59 COMMERCIAL BANKS

**28 Local Banks**
1 Foreign Trade
2 Cambodia Asia
3 Canadia
4 Vattanac
5 ACLEDA
6 Sathapana
7 Booyoung
8 PP Commercial
9 Cambodia Post
10 Chief
11 B.I.C
12 Prince
13 Chip Mong
14 Asia-Pacific
15 J Trust
16 PANDA
17 Agricultural and Rural
18 SME Bank
19 Alpha Commercial
20 SBI Ly Hour
21 Ruili
22 Wing
23 Heng He
24 Oriental
25 Bridge Bank Plc.
26 CCU
27 Heng Feng
28 IPU SEA

**11 Foreign Branch**
1 First Commercial
2 Krung Thai
3 Bank of China
4 Mega
5 ICBC
6 Taiwan
7 Bangkok
8 Kasikorn
9 Mizuho
10 Vietnam
11 Industrial bank of korea

**20 Subsidiary Banks**
1 Cambodian
2 Public
3 May Bank
4 J Trust Royal
5 Advanced Bank of Asia
6 Invest. & Devel.
7 Shinhan
8 RHB Bank
9 CIMB
10 SACOM
11 Hong Leong
12 Cathay
13 Union
14 Phillip
15 SHB
16 Bred
17 DGB
18 Woori
19 MB Bank
20 KB Prasac

### 9 Specialized Banks

**4 Locally Incorporated**
1 ANCO
2 Maritime
3 Evergrowth
4 Daun Penh

**5 Foreign Banks**
1 PHSME
2 KB Daehan
3 Angkor Capital
4 Aeon
5 Southern Capital

### 5 Representative Offices
1 Standard Chartered
2 Joint Stock Commercial
3 Sumitomo Mitsui
4 Shanghai
5 Export-Import

### 201 MICROFINANCE & RURAL CREDIT INSTISTUTION

**4 MDIs**
1 AMRET
2 AMK
3 LOLC
4 Mohanokor

**83 MFIs**
1 Seilanithih
2 Welcome
3 Maxima
4 Intean
5 Nong Hyup
6 Farmer
7 First Finance
8 Y.C.P
9 Samrithisak
10 Camma
11 Khemarak
12 Prime MF
13 Sonatra
14 Chamroeun
15 Active People
16 Bayon Credit
17 Borribo
18 Queen
19 City
20 Amatak
21 Sachak
22 ORO
23 Niron
24 Delta
25 Century
26 BAMC
27 PiphupThmey
28 Serey Oudom
29 Sambath
30 BNKC
31 Bamboo
32 Sahakrinpeap
33 Chailease royal
34 TBB
35 Royal
36 Sunny
37 Funan
38 Samporn Samakum
39 Samaky
40 Labor Care
41 CAM Capital Public
42 Kongkea Capital
43 Futaba
44 Idemitsu
45 Mothers
46 Sahaka
47 Golden Cash
48 Chokchey
49 Sabay
50 Jet's Cash Box
51 LED
52 L B P
53 Prasethpheap
54 T & Go
55 Anakut
56 Grow
57 Baitang
58 Mia
59 Leng Navatra
60 Vithey
61 Trop Khnhom
62 Khmer Capital
63 PG Development
64 JC
65 CMK
66 Rolya
67 LCH
68 Family
69 Propey
70 Sixty-Six
71 G B
72 Evergreen
73 Y.L.P
74 Sawad Rung Reung
75 Mango
76 Corich
77 Vivath Golden
78 Side Hustle
79 Soksan
80 AMZ
81 JACCS
82 East Micro Plc
83 RAFCO

**114 RCIs**
1 Chou Chivorn
2 Ministry of Rural
3 Bovor
4 Peayorb Finance
5 CEN Finance
6 Mittapheap
7 L.E.D.A Capital
8 LED-TIPS
9 DAIKOU
10 Preahkhan Aphivath
11 Krepo Finance
12 V.P Dec
13 Sereysuosdey Peanech
14 OCDAF Finance
15 Chor Meyjing
16 Hykean Capital
17 Kon Khmer Mongkul
18 Mean Chey Credit
19 Brosear
20 Meakea
21 KPCA
22 Dako
23 Samnang Protebatkar
24 Smile Capital
25 Kunapheap
26 Samreth Pech
27 B.Y.G Finance
28 Quick Amatak
29 LH
30 Baytang
31 K.D.O
32 Chum Samnang
33 CAM
34 Enteam Easy
35 Krong Khmer
36 Morodok Aphivath
37 Kalyan Aphivath
38 Phumin Credit
39 Virakboth
40 Punleu Kaksekar Khmer
41 ECK
42 S.H.G
43 R N D B
44 Phka Chhouk
45 Soksabay Heranhvatho
46 K.K.C.M
47 RADOCHICO
48 Prasithpheap Credit
49 Global Lending
50 LDA
51 Intean Neary
52 Pidaur Grow
53 Sky Light
54 Tara
55 Kon Kasekor
56 Kroursa Ennatean
57 Amatak Rongroeng
58 Khmer Angkor
59 Kuntheam
60 Sambo Trop
61 Tybotta
62 C.K
63 Right Smart
64 Samreth Credit
65 Angkor Chorpoan
66 Kakkorb
67 Smile
68 Sakal
69 Enatean Lerkstuoy Samatepheap Kruosa
70 Preah Chan
71 ONO
72 UNIDA
73 FHF Capital Plc
74 Blue
75 Khemra
76 CamFund Prathna
77 AFG
78 Mamede
79 Vireaksac
80 Racha
81 Aneaktean Molathan
82 Samrorb Samruol
83 Pishnuka
84 Prac
85 Lichou Capital
86 A.C.L.P.L
87 K E P
88 Punleu Snam Nhor Nhem
89 Reaksmey Serey Mongkul
90 Metta
91 FT Cash Express Plc
92 Reaksmey Chey Chumneas
93 Reakreay
94 C.K.L.S
95 Unitrust
96 GBIT
97 Entean Aphivath Achivkam
98 Crystal
99 S.B.E
100 C.V.A
101 ACABAR
102 Rithy
103 Samathor
104 Partner in Compassion Fund
105 Reahou
106 Sovannaphum Social Dev
107 Dhitemah
108 S.M.E.S ECO
109 Phanitda
110 OCKENDEN Metrei Entean
111 Right Place Rise Up
112 Hope Fund
113 Morakot
114 We Service

### NBC Provincial Branch
1 Phnom Penh
2 Kampong Cham
3 Sihanouk
4 Siemreap
5 Battambang
6 Banteay Meanchey
7 Svay Rieng
8 Kandal
9 Kampot
10 Kampong Thom
11 Pursath
12 Kampong Speu
13 Koh Kong
14 Ratanakiri
15 Prey Veng
16 Takeo
17 Kampong Chhnaing
18 Preah Vihear
19 Kratie
20 Stung Treng
21 Mondolkiri

### OTHERS BUSINESS

**Money Changer: 3,187**
Phnom Penh: 58
• License: 21
• Authorisation: 37
Provincial: 3,129
• License: 1
• Authorisation: 3,128

**16 Financial Leasing**
1 G.L. Finance
2 BSP Finance
3 Mega Leasing
4 Suosdey
5 KK Fund Leasing
6 TOYOTA Tsusho
7 Mobility Financing
8 I-Finance Leasing
9 Ly Hour Leasing
10 Chailease Royal
11 Komatsu Leasing
12 Kubota Leasing
13 L O D Leasing
14 Icare Leasing
15 Forward Leasing
16 We Service Leasing

**6 Third Party Processor**
1 Western Union
2 Money Gram
3 Continental Exchange Solutions, Inc. dba RIA Financial Services
4 Eurogiro A/S
5 Merchantrade Asia
6 Novus Technologies

**33 Payment Service Institutions**
1 True Money
2 Ly Hour Pay Pro
3 Pi Pay
4 Asia Cash Express
5 Seatel Financial Service
6 Speed Pay
7 ARBITRARY PAY
8 Coolbill
9 Edeel
10 Ipay88
11 Bongloy Payments
12 Tian Xu International Technology
13 Huione Pay
14 E-Money Payment Solutions
15 Dragon fly
16 Dynamic
17 Dara Sakor
18 Bai Sen Technology
19 AETRINO GLOBAL
20 Paragon Payment
21 Kess Innovation
22 LM pay
23 One Pay Plc
24 Lync Pay Payment
25 U-Pay Digital
26 Starpay Fintech
27 Lanton International
28 Wing Money
29 Clik Payment
30 Sunpay
31 Cai Fu Tong
32 Payon
33 Jin Hong Zhen

**1 Credit Bureau**
1. CBC

បាគង
BAKONG



រៀបចំបោះពុម្ពដោយ ធនាគារជាតិនៃកម្ពុជា